**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2021, 12:53
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញ**
**នៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី

Laure DESFORGES
Isabelle DURAND
Emmanuel ALTIT
Martine JACQUIN
Daniel LOSQ
Christine MARTINEAU

<u>នៅចំពោះមុខ</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE- MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

ទី ស្រ៊ីនណា

វ៉េន ពៅ

Lyma NGUYEN
Mahesh RAI
Nushin SARKARATI

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង

Brenda J. HOLLIS

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

គង់ សំអុន

Anta GUISSÉ

# ១. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) ស្នើសុំការសម្រេចពីអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) ដើម្បីអាចដំណើរការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ពាក់ព័ន្ធនឹងសមាជិកក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលរួមគ្នា (“ដើមបណ្តឹងរដ្ឋប្បវេណី”)។ សំណើនេះត្រូវបានដាក់អនុលោមតាមវិធាន ១០៤*ស្ទួន* និង ៩២ នៃវិធានផ្ទៃក្នុង ដោយមានការជំរុញពីអង្គជំនុំជម្រះសាលាដំបូង នៅក្នុងដីការបស់ខ្លួនបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងមកជាឯកសារសាធារណៈ[1]។

2. ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ គឺជាបញ្ហាធំធេងណាស់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ វាជាចំណុចស្នូលនៃកេរតំណែលរបស់តុលាការ។ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនឹងកំណត់ថាលទ្ធផលការងាររបស់តុលាការត្រូវបានដាក់ជាសាធារណៈបានកម្រិតណា ដើម្បីឱ្យ អ.វ.ត.ក មានឥទ្ធិពលពិតប្រាកដ និងជាយូរអង្វែង។ ក៏ប៉ុន្តែ បញ្ហានេះក៏មានផលប៉ះពាល់ផងដែរដល់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ដែលមានព័ត៌មានរសើបផ្ទាល់ខ្លួនរបស់ពួកគាត់នៅក្នុងសំណុំរឿង និងអាចតម្រូវឱ្យធ្វើការកោសលុបខ្លះ។

3. អនុលោមតាមមាត្រា ១២.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង (“សេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ”) អង្គជំនុំជម្រះត្រូវពិនិត្យលើការធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះកំណត់ហេតុនៅក្នុងសំណុំរឿង ០០២។ ទោះបីអង្គជំនុំជម្រះអាចកំណត់ជាចុងក្រោយទៅលើចំណាត់ប្រភេទឯកសារជាក់លាក់ ក្រោយពេលចេញសាលដីកាស្ថាពររបស់ខ្លួនក៏ដោយ ក៏សារណាលម្អិត និងសំណើនានាពាក់ព័ន្ធនឹងស្ថានភាពនៃសម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ត្រូវការពេលវេលាដើម្បីរៀបចំដែរ។ ហេតុនេះ សហមេធាវីនាំមុខស្នើសុំការណែនាំដែលនឹងធ្វើឱ្យការងារនេះអាចសម្រេចបានក្នុងអំឡុងពេលនេះ។ នៅក្នុងសំណើនេះ សហមេធាវីនាំមុខសូម៖

(ក) ផ្តល់ជូននូវទិដ្ឋភាពទូទៅនៃប្រវត្តិនីតិវិធី និងសាវតានៃសំណើនេះ។

(ខ) លើកឡើងនូវក្របខណ្ឌគតិយុត្តិពាក់ព័ន្ធ ក្នុងកម្រិតដែលមានការបញ្ជាក់ច្បាស់ពីអត្ថបទ

---

[1] ឯកសារ **E467/6** ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងជាឯកសារសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ១១។ សូមើលផងដែរ កថាខណ្ឌ ៩។

ច្បាប់របស់ អ.វ.ត.ក និងបង្ហាញនូវចំណុចមិនប្រាកដប្រជានានាដែលលេចធ្លោ។

(គ) បង្ហាញនូវប្រភេទឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងដែលលើកឡើងនូវបញ្ហាឯកជនភាព និងអាចតម្រូវឱ្យធ្វើការកោសលុបខ្លះ មុនពេលយកសម្ភារនៅក្នុងសំណុំរឿងមកដាក់ជាសាធារណៈ។

(ឃ) ស្នើសុំគោលការណ៍នានាសម្រាប់ការប្រើប្រាស់ ក្នុងចំណាត់ប្រភេទឡើងវិញចំពោះសម្ភាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ដែលរក្សាតុល្យភាពរវាងតម្លាភាព និងឯកជនភាព។ និង

(ង) ស្នើសុំឱ្យមានដំណើរការមានសមាមាត្រ និងមានប្រសិទ្ធផល ពីដំណើរការចំណាត់ប្រភេទឯកសារឡើងវិញ។

4. ឧបសម្ព័ន្ធសម្ងាត់ ក ដែលភ្ជាប់ជាមួយសំណើ មានតារាងបញ្ជីឧទាហរណ៍នៃឯកសារដើមបណ្ដឹងរដ្ឋប្បវេណី ដែលបង្ហាញពីតម្រូវការសម្រាប់ដំណើរការធ្វើចំណាត់ថ្នាក់ប្រភេទឯកសារឡើងវិញដោយប្រុងប្រយ័ត្នពាក់ព័ន្ធនឹងការពិនិត្យឯកសារបុគ្គល និងឱកាសសម្រាប់ភាគីដែលរងផលប៉ះពាល់ ដែលត្រូវបានដឹងឮ។ ឧទាហរណ៍ទាំងនេះ ត្រូវបានបញ្ចូលក្នុងបញ្ជីដាច់ដោយឡែកមួយសម្រាប់ភាពងាយស្រួល ប៉ុន្តែវាក៏ដើម្បីការពារព័ត៌មានរសើបដែលមាននៅក្នុងឯកសារ ដែលបច្ចុប្បន្នត្រូវបានចាត់ចំណាត់ថ្នាក់ជាសាធារណៈ ហើយដែលសហមេធាវីនាំមុខជឿថាឯកសារទាំងនោះ អាចទាមទារឱ្យមានការកោសលុប។ សហមេធាវីនាំមុខ សង្កត់ធ្ងន់ថា ឯកសារដែលមានរាយឈ្មោះក្នុងឧបសម្ព័ន្ធ ក មិនមែនជាបញ្ជីពេញលេញនៃឯកសារដែលទាមទារការពិនិត្យឡើងវិញ និងការកោសលុបនោះទេ។ ការពិនិត្យឡើងវិញពេញលេញនៃសំណុំរឿង នឹងត្រូវការពេលវេលា ហើយមិនទាន់អាចធ្វើទៅបាននៅឡើយទេ។ ដូច្នេះឧបសម្ព័ន្ធ ក មានគោលបំណងដើម្បីផ្ដល់នូវឧទាហរណ៍ជាក់ស្ដែងតែប៉ុណ្ណោះ ដែលវាត្រូវបានសង្ឃឹមថានឹងបង្ហាញពីតម្រូវការសម្រាប់ការពិនិត្យឡើងវិញយ៉ាងប្រុងប្រយ័ត្ន និងពេញលេញ។

5. សហមេធាវីនាំមុខយល់ដឹងអំពីបន្ទុកការងារយ៉ាងធ្ងន់ធ្ងររបស់អង្គជំនុំជម្រះ និងដឹងពីធនធានតិចតួចដែលភាគីអាចប្រើប្រាស់បាន។ នាពេលនេះ សំណើនេះត្រូវបានធ្វើឡើងដោយសារមានការប្រមើលមើលថា ដំណើរការពិនិត្យលើឯកសារក្នុងសំណុំរឿងក្នុងគោលបំណងដើម្បីធ្វើចំណាត់ប្រភេទឡើងវិញយ៉ាងយកចិត្តទុកដាក់ ទាមទារនូវការចំណាយពេលយ៉ាងច្រើនសន្ធឹកសន្ធាប់ ដូចដែលនឹងពន្យល់ខាងក្រោម។ ការបញ្ជាក់បំភ្លឺពីគោលការណ៍នានាជាធរមាន និងដំណើរការ ពេលនេះនឹងជាការបំពេញការងារបានមួយភាគធំ មុនពេលអង្គជំនុំជម្រះចេញសាលដីកាស្ថាពររបស់ខ្លួន។ ប្រសិនបើ

ដំណើរការនេះមិនចាប់ផ្តើមនាពេលនេះទេ មានហានិភ័យដែលថា វាអាចនាំឱ្យមានការពន្យារពេលយ៉ាងច្រើនក្នុងការបញ្ចប់ការងាររបស់តុលាការក្នុងសំណុំរឿង ០០២ ជាពិសេស ប្រសិនបើការយល់ដឹងពីសំណុំរឿងរបស់ភាគីបច្ចុប្បន្នត្រូវបានបាត់បង់ តាមរយៈការកាត់ធនធាន ក្នុងពេលនេះ ហើយមេធាវីថ្មីៗត្រូវចំណាយពេលឱ្យស៊ាំទៅនឹងសំណុំរឿង។

6. ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែមានឱកាសត្រូវបានដឹងឮអំពីជោគវាសនានៃព័ត៌មានផ្ទាល់ខ្លួនរបស់ខ្លួន។ នេះជាសំណួរគោល៖ គោលបំណងសំខាន់នៃការចូលរួមរបស់ជនរងគ្រោះ ដែលជារឿយៗត្រូវបានអះអាងថាជាសមទ្ធិផលមួយក្នុងចំណោមសមិទ្ធផលរបស់ អ.វ.ត.ក[2] គឺជាការអនុញ្ញាតឱ្យអ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយការសម្រេចរបស់តុលាការត្រូវបានដឹងឮជាមុន[3]។ ប៉ុន្តែវាក៏ជាសំណួរពាក់ព័ន្ធនឹងភាពជាក់ស្តែងផងដែរ៖ ក្នុងករណីជាច្រើនដែលបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់ដែលជាព័ត៌មានត្រូវការពារនឹងតម្រូវឱ្យដាក់បញ្ចូលពីអ្នកពាក់ព័ន្ធ[4]។

7. សហមេធាវីនាំមុខទទួលស្គាល់ថា ដំណើរការសមរម្យមួយសម្រាប់ការចាត់ចំណាត់ថ្នាក់ឡើងវិញនូវឯកសារសំណុំរឿង ០០២ ដែលរួមបញ្ចូលទាំងសវនាការពីបណ្តាភាគីនានា នឹងទាមទារឱ្យមានធនធាន។ នេះគឺជៀសមិនរួច។ វាមិនមែនជាហេតុផលល្អក្នុងការបង្វែរ ពន្យារ ឬអនុវត្តក្នុងទម្រង់មួយមិនសមរម្យនោះទេ នូវដំណើរការដែលចាំបាច់ចំពោះកេរ្តិ៍ដំណែលរបស់តុលាការ។ ដំណើរការនេះដែលនឹងកំណត់ថាតើ*ភាពទូលំទូលាយ*និងគុណភាពបណ្ណសាររបស់តុលាការយ៉ាងណា និងជាពិសេសថាតើបណ្ណសារបំពេញតាមស្តង់ដារ*សីលធម៌*មូលដ្ឋានទាក់ទងនឹងការការពារឯកជនភាពដែរឬយ៉ាងណា។

8. ជាការពិត សហមេធាវីនាំមុខសង្ឃឹមថា ការណែនាំច្បាស់លាស់ និងទាន់ពេលវេលាពីអង្គជំនុំជម្រះ

---

[2] សូមមើលឧទាហរណ៍៖ សេចក្តីប្រកាសពត័មាន របស់ អ.វ.ត.ក ៖ សហចៅក្រមរបាយការណ៍ដាក់ជូនរបាយការណ៍របស់ខ្លួនស្តីពីមុខងារនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ [ឧបសម្ព័ន្ធ ១]

[3] សេចក្តីប្រកាសអំពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៤០/៣៤ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ កថាខណ្ឌ៦(ខ)។

[4] នេះមិនត្រឹមតែជាបញ្ហានៃសុំការយល់ព្រមប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការយល់ដឹងអំពីព័ត៌មាននៅក្នុងឯកសារ និងកម្រិតនៃភាពរសើបរបស់វាផងដែរ។ ឧទាហរណ៍៖ ព័ត៌មានរសើបជាក់ស្តែងខ្លះអាចត្រូវបានស្គាល់ដល់គ្រួសារ និងសហគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ តាមធម្មតាគឺមិនមានភាពច្បាស់លាស់នៅក្នុងឯកសារ ថាតើមានហានិភ័យក្នុងការធ្វើឱ្យមានជម្លោះឬការសងសឹកពីជនដែលត្រូវបានកំណត់ថាជាជនប្រព្រឹត្ត។ រឿងនេះគឺស៊ីសងទៅលើកាលៈទេសៈនៃបុគ្គល និងទំនាក់ទំនងរបស់ពួកគាត់ ដែលកម្រមានការលើកឡើងនៅក្នុង ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ ឬទម្រង់បែបបទព័ត៌មានបន្ថែម។

លើបញ្ហាសំខាន់នេះ នឹងអាចជម្រុញឱ្យម្ចាស់ជំនួយផ្ដល់នូវធនធានដែលអាចឱ្យការងារធ្វើចំណាត់ថ្នាក់ឡើងវិញ អាចប្រព្រឹត្តទៅបានសមស្របនិងចាប់ផ្ដើមឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីជៀសវាងការពន្យារពេល។

## ២. ប្រវត្តិនីតិវិធី និងបរិបទ

### *២.១ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០២ មកទល់នឹងពេលនេះ*

9. នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា៖

> គិតត្រឹមពេលបញ្ចប់នៃការដាក់សេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ឯកសារចំនួន ១៤.៤៧៦ និងសម្ភារមួយចំនួនទៀតដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងនោះ គឺនៅតែជាឯកសារ "សម្ងាត់" ដដែល។ ភាគច្រើនលើសលប់នៃសម្ភារទាំងនោះនៅតែរក្សាចំណាត់ថ្នាក់ដដែល ជាចំណាត់ថ្នាក់ដែលត្រូវបានចាត់ថ្នាក់ដោយស្វ័យប្រវត្តិ ក្នុងអំឡុងកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង ០០២ ប៉ុន្តែឯកសារជាច្រើនដែលត្រូវបានដាក់ដេញដោលក្នុងសវនាការសាធារណៈ ត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ និងបញ្ចូលក្នុងគេហទំព័ររបស់តុលាការ ដែលភាគីអាចបើកមើលបាន។ ទោះបីជាយ៉ាងនេះក្ដី យុត្តិកម្មជាក់លាក់មួយចំនួននៃការមិនបង្ហាញឯកសារសាធារណៈ គឺនៅតែមានសុពលភាពដដែល ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារ ដែលត្រូវបានប្រមូល និងបានធ្វើឡើងក្នុងអំឡុងពេលកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង ០០២ លែងបង្កជាហានិភ័យនៃការរំលោភទៅលើសិទ្ធិរបស់ភាគី ឬសុចរិតភាពនៃកិច្ចស៊ើបសួរទៀតហើយ។ ហេតុដូច្នេះ ដើម្បីឈានដល់ការចេញសាលក្រម និងការពឹងផ្អែកលើ និង/ឬការយោងទៅលើព័ត៌មានដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាសាធារណៈនោះ អង្គជំនុំជម្រះត្រូវពិចារណាថា តើមានយុត្តិកម្មណាមួយចំពោះការរក្សាការសម្ងាត់ដែលបន្លាយហួសពីការរក្សាការសម្ងាត់នៅក្នុងអំឡុងកិច្ចស៊ើបសួរដែរឬទេ។ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថា ការសម្ងាត់លែងមានភាពចាំបាច់ទៀតហើយ សម្រាប់ឯកសារដែលបានបង្ហាញជាសាធារណៈនៅក្នុងសាលក្រមនេះ[5]។

---

[5] ឯកសារ **E465** សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៣៤។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅត្រង់ជើងទំព័រ ៧៨ នៃកថាខណ្ឌដដែលថា "កន្លងមក នៅពេលអង្គជំនុំជម្រះបានចាត់ចំណាត់ថ្នាក់ឡើងវិញលើផ្នែកជាក់លាក់មួយចំនួននៃ

10. ក្រោយពេលចេញសាលក្រមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញភាគី អង្គបុរេជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេត "ផ្តល់មតិយោបល់អំពីភាពចាំបាច់ ឬមិនចាំបាច់ក្នុងការរក្សា" ស្ថានភាពសម្ងាត់នៃឯកសារមួយចំនួន (ទោះបីជាក់ស្តែងមិនទាំងអស់ក៏ដោយ[6]) ដែលបានលើកយោងនៅក្នុងសាលក្រម[7]។ បន្ទាប់ពីមានសំណើពីសហមេធាវីនាំមុខដែលថា មាត្រា ៧.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទត្រូវយកមកអនុវត្ត ដើម្បីកោសលុបនូវឯកសារស្តីពីព័ត៌មានទំនាក់ទំនង អត្តសញ្ញាណផ្ទាល់ខ្លួន ទាក់ទិននឹងទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ និងទម្រង់បែបបទព័ត៌មានបន្ថែម[8] អង្គជំនុំជម្រះសាលាដំបូង

> បានកំណត់អត្តសញ្ញាណពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទព័ត៌មានបន្ថែមជាច្រើននៅក្នុងឧបសម្ព័ន្ធ (ក) ដែលអាចតម្រូវឱ្យមានការកោសលុបចំពោះព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់ម្ចាស់បណ្តឹង និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមមាត្រា ៧.៤ នៃសេចក្តីណែនាំអនុវត្ត។ ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងពុំមានបុគ្គលិកនិងពេលវេលាគ្រប់គ្រាន់ដើម្បីវាយតម្លៃនិងកោសលុបឯកសារទាំងនេះទេ។ ហេតុនេះ អង្គជំនុំជម្រះបានដកឯកសារពាក់ព័ន្ធចេញពីឧបសម្ព័ន្ធ (ក) និងបញ្ចូលឯកសារទាំងនោះទៅក្នុង ឧបសម្ព័ន្ធ ៥ នៃដីកាបង្គាប់នេះវិញ។ *អង្គជំនុំជម្រះតុលាការកំពូលមានភារកិច្ចពិនិត្យឡើងវិញទៅលើភាពសមស្របនៃការធ្វើចំណាត់ថ្នាក់នៃឯកសារទាំងនេះរួមមាន ការកោសលុបនានា តាមការផ្តួចផ្តើមរបស់ខ្លួន ឬនៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ លើកលែងតែ*

---

ឯកសារនៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា ការបង្ហាញផ្នែកនេះមិនប៉ះពាល់ដល់ការចាត់ចំណាត់ថ្នាក់ឡើងវិញពាក់ព័ន្ធនឹងផ្នែកដែលមិនត្រូវបង្ហាញ និងព័ត៌មានក្នុងឯកសារ ឬសម្ភារៈដទៃទៀតទាំងមូលនោះឡើយ"។

[6] សហមេធាវីនាំមុខកត់សម្គាល់ថា ឯកសារសម្ងាត់ខ្លះដែលបានយកមកយោងនៅក្នុងសាលក្រមនេះ ហាក់ដូចជាពុំបានដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធនានាដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យដាក់សារណានោះទេ។ វាមិនច្បាស់ថាតើយោងលើមូលដ្ឋានអ្វី ទើបអង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់បញ្ចូល ឬដកចេញឯកសារនានាពីឧបសម្ព័ន្ធទាំងនោះទេ។

[7] ឯកសារ **E467** អនុស្សរណៈពីអង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា: ឯកសារសម្ងាត់នៅក្នុងសាលក្រមលើសំណុំរឿង ០០២/០២ ដែលស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញជា ឯកសារសាធារណៈ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩។ សារ **E467/6** ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងជា ឯកសារសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ១។

[8] ឯកសារ **E467/2** មតិយោបល់ និងការជំទាស់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា: "ឯកសារសម្ងាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ ដែលស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញជា ឯកសារសាធារណៈ" ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩ កថាខណ្ឌ២។

*សហមេធាវីនាំមុខ (ឬភាគីផ្សេងទៀត) ដាក់សំណើសុំបែបនេះតាំងពីដំបូងមក ...*[9]។

11. ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងពិតជាបានធ្វើចំណាត់ប្រភេទឯកសារប្រភេទផ្សេងទៀត ជាឯកសារសាធារណៈ[10]។

12. សហមេធាវីនាំមុខកត់សម្គាល់ថា ពុំមានដំណើរការប្រហាក់ប្រហែលគ្នាពាក់ព័ន្ធនឹងឯកសារនានា ដែលបានលើកយោងនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ទេ[11]។

## *២.២ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿងផ្សេងទៀត*

13. សហមេធាវីនាំមុខមិនមានតួនាទីផ្ទាល់នៅក្នុងសំណុំរឿងផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក និងមិនមានសិទ្ធិចូលប្រើប្រាស់ឯកសារសំណុំរឿងសម្ងាត់ក្រៅពីសំណុំរឿង ០០២ ឡើយ។ ដោយមិនអាចចូលទៅក្នុងកំណត់ត្រាសម្ងាត់បាន វាជាការពិបាកក្នុងការសន្និដ្ឋានភាពជាក់លាក់នូវវិធីសាស្ត្រអ្វីដែលបានកំណត់យកនៅក្នុងសំណុំរឿងផ្សេង។ ទោះជាយ៉ាងណាក៏ដោយ ការសង្កេតខាងក្រោមអាចត្រូវបានធ្វើឡើងដោយផ្អែកលើសម្ភារៈដែលត្រូវបានចាត់ថ្នាក់ជាសាធារណៈរួចហើយ។

14. នៅក្នុងសំណុំរឿង ០០១ *សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង* របស់អង្គជំនុំជម្រះ បានចេញនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ក្រោយពេលចេញសាលដីកាសំណុំរឿង ០០១ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២[12]។ សេចក្តីសម្រេចនេះបានទទួលស្គាល់ថា ភាគីគួរមានឱកាសក្នុងការបញ្ចេញមតិយោបល់លើបញ្ហាស្តីពីចំណាត់

---

[9] ឯកសារ **E467/6** ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងជា ឯកសារសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ១១។ [*សេចក្តីបញ្ជាក់បន្ថែម*]។

[10] សូមមើលខាងក្រោមបន្ថែមទៀត ក្នុងផ្នែក ៤.៣។

[11] ដូចដែលខ្លួនបានសម្រេចក្នុងសំណុំរឿង ០២/០២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេច*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*ថា ព័ត៌មានមួយចំនួនចេញពីឯកសារសម្ងាត់ អាចត្រូវបានសំអាងថាជាព័ត៌មានសាធារណៈនៅក្នុងសាលក្រមរបស់ខ្លួន ប៉ុន្តែ ប៉ុន្តែពុំបានកែប្រែការធ្វើចំណាត់ប្រភេទឯកសារដែលបានខ្លួនកំណត់នោះទេ: ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៣៩ និងជើងទំព័រ ១០៦។

[12] សំណុំរឿង **001** ឯកសារ **F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២។ អង្គជំនុំជម្រះក៏បានចេញសេចក្តីសម្រេចបន្ទាប់ ក្នុងឆ្នាំ២០១៥ ដែលជាចម្លើយទៅសំណើជាក់លាក់មួយសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញ ទៅលើវត្ថុតាងមួយក្នុងសំណុំរឿង ០០១: សំណុំរឿង **001** ឯកសារ **F31/1** [កោសលុបជាសាធារណៈ] សេចក្តីសម្រេចស្តីពីការដាក់ចំណាត់ថ្នាក់ឡើងវិញនូវខ្សែវីដេអូលេខ **E3/247R** និងផ្លាស់ប្តូរ និងកែប្រែទៅលើវិធានការការពារដែលជាប់ពាក់ព័ន្ធ ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៥។

ប្រភេទឯកសារឡើងវិញ[13] តែហាក់ដូចជាពុំមានសារណានានាធ្វើឡើងក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីទេ ប្រហែលដោយសារដំណើរការនេះបានកើតឡើងក្រោយពេលបញ្ចប់សំណុំរឿង[14]។ (សហមេធាវីនាំមុខកត់សម្គាល់ថា ពួកគេពុំបានចូលរួមក្នុងសំណុំរឿង ០០១ ទេ)។ អង្គជំនុំជម្រះបានបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញ ទៅលើទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ ("VIFs") ទាំងអស់មកជាឯកសារសាធារណៈ[15] ទោះបីទម្រង់បែបបទទាំងនោះត្រូវបាន ឬមិនត្រូវបានលើកយោងនៅក្នុងសេចក្តីសម្រេច ឬសារណាសាធារណៈក៏ដោយ ដោយពុំបានពន្យល់អំពីមូលហេតុដែលនាំឱ្យអង្គជំនុំជម្រះប្រកាន់យកវិធីសាស្ត្រនោះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទេ[16]។ មានការបង្គាប់ឱ្យធ្វើការកោសលុបតិចតួចទាក់ទងនឹង "ព័ត៌មានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះ ដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងក្នុងករណីដែលព័ត៌មានបែបនេះត្រូវបានសរសេរបញ្ចូលនៅក្នុងបណ្តឹងរបស់ជនរងគ្រោះ"[17]។

15. ការពិនិត្យលើសំណុំរឿង ០០១ ជាសាធារណៈបង្ហាញថា ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាសាធារណៈ ឬពាក្យសុំតាំងខ្លួនជាដើមបណើងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងនោះ[18] ត្រូវបានកោសលុបដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់ជនរងគ្រោះមួយចំនួន និងភាគីតតិយជន ជាពិសេសព័ត៌មានទំនាក់ទំនងលម្អិត និងអត្តសញ្ញាណ[19]។ ដូច្នេះដែរ ចំពោះឯកសារព័ត៌មានបន្ថែម[20] លិខិតតំណាងដោយអាណត្តិរបស់ដើមបណើងរដ្ឋប្បវេណី[21] និងលិខិតទទួល

---

[13] *ដូចខាងលើ* កថាខណ្ឌ ២-៤។

[14] សម្រាប់មូលហេតុដែលមិនមានលក្ខណៈមិនច្បាស់លាស់ចេញពីសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានអញ្ជើញអង្គភាពគាំទ្រជនរងគ្រោះ ជាជាងអញ្ជើញសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឱ្យផ្តល់មតិយោបល់លើបញ្ហានេះទៅវិញ។ .

[15] ពេលខ្លះ ទម្រង់បែបបទព័ត៌មានជនរងគ្រោះទាំងនេះត្រូវបានសំអាងថាជា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

[16] សំណុំរឿង **០០១** ឯកសារ **F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៧។

[17] ដូចខាងលើ កថាខណ្ឌ ៧(ខ)( i)។

[18] បុគ្គលទាំងឡាយដែលត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុង**សំណុំរឿង ០០១** ឯកសារ **F28.2** សាលដីកាឧបសម្ព័ន្ធ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ក្នុងសាលក្រម ឬសាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២។ ឯកសារជនរងគ្រោះដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាសាធារណៈក្នុងសំណុំរឿង ០០១ រួមមានឯកសារដែលដាក់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ក៏ដូចជាឯកសារផ្សេងទៀតដែលត្រូវបានស្វែងរក ប៉ុន្តែមិនត្រូវបានផ្តល់ ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

[19] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ១, ៥, ១១, ១២, ១៤, ១៥។

[20] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ២៧, ២៨, ២៩។

[21] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ២, ៣, ៦, ១៦។

ស្គាល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[22] ដែលមានផ្ទុកនូវព័ត៌មានផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

16. ក៏ប៉ុន្តែ ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះមួយចំនួនតូច ត្រូវបានចាត់ចំណាត់ថ្នាក់ជាសាធារណៈក្នុងទម្រង់ដែលមិនបានកោសលុប[23] ។ ថ្វីបើនេះជាភាពជាក់ស្តែងក៏ដោយក៏ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះទាំងនេះមានផ្ទុកព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលនៅក្នុងសំណួរ ហើយបើទោះបីជាត្រូវរក្សាការសម្ងាត់[24] ប៉ុន្តែក៏មានព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលមួយចំនួន ក៏ត្រូវបានរកឃើញនៅក្នុងសំណុំរឿង ០០២ ។ ជីវប្រវត្តិ និងចម្លើយសារភាពដែលមិនត្រូវបានបង្ហាញជាសាធារណៈ ដោយសារៈមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងព្រោះវាត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្ម (សូមមើលកថាខណ្ឌទី ៤២ ខាងក្រោម) ភាគច្រើនត្រូវបានចាត់ថ្នាក់ជាសាធារណៈ[25] ទោះបីជាឯកសារមួយចំនួនតូចត្រូវបានកោសលុបដោយផ្នែកក៏ដោយ[26] ។ ប្រភេទព័ត៌មានដែលត្រូវបានកោសលុបក៏មានភាពខុសគ្នាដែររវាងឯកសារតែមួយ ឬឯកសារមួយនិងឯកសារមួយទៀត[27] ហើយគេពុំដឹងច្បាស់ពីរបៀបកំណត់ឱ្យកោសលុបនោះទេ។ ក្នុងករណីខ្លះ ពត៌មានដែលត្រូវបានកោសលុបក្នុងភាសាមួយនៃឯកសារ គឺមិនត្រូវបានកោសលុបក្នុងភាសាផ្សេងទៀតនៃឯកសារដដែលនោះ[28]។ ជាងនេះទៀត របាយការណ៍ជាច្រើនរបស់ "អង្គភាពជនរងគ្រោះ" ទៅលើទម្រង់

[22] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ៤, ១៩។

[23] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ២០, ២១។ សូមមើលផងដែរ ឧបសម្ព័ន្ធ ក ផ្នែក ២៥ ភាសាបារាំង។

[24] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ២១។

[25] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ១០, ៣០។

[26] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ៣១។

[27] ឧទាហរណ៍ នៅក្នុងឯកសារមួយចំនួន អាយុ ឬថ្ងៃខែឆ្នាំកំណើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកោសលុប ខណៈពេលឯកសារផ្សេងទៀតមិនបានកោសលុប។ ឈ្មោះឪពុកម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានកោសលុប ខណៈដែលឯកសារខ្លះទៀតមិនបានកោសលុប។ នៅក្នុងឯកសារមួយចំនួនទៀត ត្រង់កន្លែងដែលមានចុះហត្ថលេខា ត្រូវបានកោសលុប ខណៈដែលនៅក្នុងឯកសារផ្សេងទៀតមិនបានកោសលុបទេ។ ប្រៀបធៀបជាឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ១ និង ៥ ឬ ឧបសម្ព័ន្ធ ក ផ្នែក ១៤ និង ១៧។ ទាក់ទងនឹងភាពមិនស៊ីសង្វាក់គ្នាផ្ទៃក្នុង សូមមើលឧទាហរណ៍ ឯកសារដែលអាសយដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកោសលុប នៅក្នុងផ្នែកមួយនៃឯកសារ ប៉ុន្តែទំព័របន្តបន្ទាប់ទៀត មិនបានកោសលុប (ឧបសម្ព័ន្ធ ក ត្រង់ផ្នែក ៧, ២៥, ២៦) ។ ក្នុងករណីខ្លះ សំណុំឯកសារ មានការកោសលុបខុសគ្នាទៅលើឯកសារតែមួយ ។ សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ត្រង់ផ្នែក ២២ និង ២៣ និង ឧបសម្ព័ន្ធ ក ត្រង់ផ្នែក ២៤ និង ២៥។

[28] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ២២, ២៣, ២៤។ ឧបសម្ព័ន្ធ ក ផ្នែក ២៥ មានប្រភេទឯកសារដែលត្រូវបានកោសលុបជាភាសាខ្មែរ និងភាសាអង់គ្លេស តែមិនត្រូវបានកោសលុបទាល់តែសោះក្នុងភាសាបារាំង។

បែបបទស្តីពីព័ត៌មានជនរងគ្រោះត្រូវបានដាក់ជាសាធារណៈដោយគ្មានការកោសលុបទេ ទោះបីមានព័ត៌មានមួយចំនួនត្រូវបានកោសលុបពីទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះទាំងនោះក៏ដោយ។ ឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីក៏មានការកោសលុបមិនស៊ីសង្វាក់គ្នាដែរ[29]។ គេពុំដឹងច្បាស់ឡើយថា តើទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះបន្ថែម ឬឯកសារផ្សេងទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ និងមានតែនៅក្នុងសំណុំរឿងសម្ងាត់ ឬយ៉ាងណា។ ព័ត៌មានរសើបផ្ទាល់ខ្លួនក្រៅពីព័ត៌មានទំនាក់ទំនងលម្អិតហាក់ដូចជាមិនត្រូវបានពិចារណាសម្រាប់ការកោសលុបទេ៖ ឧទាហរណ៍ ពត៌មានដែលសំដៅលើស្ថានភាពសុខភាព និង/ឬការព្យាបាលរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានកោសលុបទេ[30]។

17. ការធ្វើចំណាត់ប្រភេទឡើងវិញមួយចំនួនក៏ត្រូវបានធ្វើឡើងដោយអង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/០១ និង សំណុំរឿង ០០៤/០២ ដែរ[31]។ នៅក្នុងសំណុំ

---

[29] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ត្រង់ផ្នែក ៩, ១៣ និង ១៨ ដែលលាតត្រដាងព័ត៌មានឯកជនមួយចំនួនដែលត្រូវបានកោសលុបពីឯកសារផ្សេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែមួយ (ឧបសម្ព័ន្ធ ក ផ្នែក ៥, ១១, ១៤) ។

[30] សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធ ក ត្រង់ផ្នែក ១, ៥, ១២, ១៣, ២០, ២១, ២៤, ២៥, ២៧។

[31] **សំណុំរឿង ០០៣** ឯកសារ **D266/28 & D267/36** សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១។ **សំណុំរឿង ០០៣** ឯកសារ **D266/29 & D267/37** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៣" ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១។ **សំណុំរឿង ០០៣** ឯកសារ **D274** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៣" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។ **សំណុំរឿង ០០៤/០១** ឯកសារ **D315** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤/០១" ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១។ **សំណុំរឿង ០០៤/០១** ឯកសារ **D316** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤/០១" ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១។ **សំណុំរឿង ០០៤/០១** ឯកសារ **D317** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤/០១" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។ **សំណុំរឿង ០០៤/០២** ឯកសារ **D359/21 & D360/30** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤, ០០៤/០១ និង ០០៤/០២" ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩។**សំណុំរឿង ០០៤/០២** ឯកសារ **D359/38 & D360/47** សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០៤/២ របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។ **សំណុំរឿង ០០៤/០២** ឯកសារ **D365** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤/០២" ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១។ **សំណុំរឿង ០០៤** ឯកសារ **D381/43 & D382/42** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី៥ ខែឧស

រឿង ០០៤/០២ ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះមួយចំនួនត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ ដោយមិនបានធ្វើការកោសលុបទេ ទោះបីជាព័ត៌មាន មូលដ្ឋានផ្ទាល់ខ្លួនក៏ដោយដូចជាអាសយដ្ឋាន លេខទូរស័ព្ទ និងលេខអត្តសញ្ញាណប័ណ្ណ[32]។ ចំណុចនេះកើតឡើងទោះបីបុគ្គលពាក់ព័ន្ធនានាក៏ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ហើយដូចគ្នាបេះបិទ ឬស្ទើរតែដូចគ្នាបេះបិទទៅនឹងទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះផ្សេងទៀត ដែលស្ថិតនៅជាឯកសារសម្ងាត់នៅក្នុងសំណុំរឿង ០០២ ក៏ដោយ[33]។ ច្បាប់ចម្លងនៃទម្រង់បែបបទព័ត៌មានជនរងគ្រោះសម្ងាត់ទាំងនេះ ក៏មាននៅក្នុងសំណុំរឿង ០០៣, ០០៤ និង ០០៤/១។[34] បុគ្គលម្នាក់ក្នុងចំណោមផ្សេងទៀតជាដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០១ ដែលទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះក្នុងសំណុំរឿង ០០១ ត្រូវបានចាត់ថ្នាក់ឡើងវិញជាឯកសារសាធារណៈជាមួយនឹងការកោសលុបនូវព័ត៌មានផ្ទាល់ខ្លួន។[35] សហមេធាវីនាំមុខបានលើកឡើងបញ្ហានេះជូនអង្គបុរេជំនុំជម្រះ តែអង្គបុរេជំនុំជម្រះពុំបានចាត់វិធានការណាមួយទេ[36]។ សហមេធាវីនាំមុខកត់សម្គាល់ថា អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញជាច្រើនទៀតនាពេលថ្មីៗនេះ ហេតុនេះ ការងារនេះទំនងជានៅតែបន្តទៅមុខទៀត។ ហេតុនេះ មានភាពចាំបាច់ឱ្យមានការសម្របសម្រួលភ្លាមៗ ដើម្បីឱ្យសម្ភារផ្ទាល់ដែលត្រូវបានការពារយ៉ាងត្រឹមត្រូវនៅក្នុងសំណុំរឿង ០០២ មិនត្រូវបានដាក់បង្ហាញដោយមិនត្រឹមត្រូវ តាមរយៈការធ្វើចំណាត់ប្រភេទឡើងវិញនៃសម្ភារដែលមានក្នុងសំណុំរឿងផ្សេងទៀត។

## *២.៣ បរិបទពាក់ព័ន្ធនឹងបណ្តឹងសារ និងមុខងារនៅសេសសល់របស់តុលាការ*

---

ភា ឆ្នាំ២០២១។ **សំណុំរឿង ០០៤** ឯកសារ **D387** អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ "ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។

[32] សូមមើលឧបសម្ព័ន្ធ ក ផ្នែក ៣២-៣៨។

[33] ផ្នែក ៣២-៣៧ នៅក្នុងឧបសម្ព័ន្ធ ក គឺជា ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ ដែលបង្ហាញក្នុងទម្រង់ដូចគ្នាបេះបិទក្នុងសំណុំរឿង ០០២ (សម្ងាត់) និងក្នុងសំណុំរឿង ០០៤/២ (ចាត់ថ្នាក់ឡើងវិញ ដោយមិនមានការកោសលុប)។ ផ្នែកទី 13 នៅក្នុងឧបសម្ព័ន្ធ ក សំដៅលើ ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះពីរដែលដាក់ដោយបុគ្គលតែម្នាក់ មួយក្នុងសំណុំរឿង 002 (សម្ងាត់) និងមួយក្នុងសំណុំរឿង ០០៤/ ០២ (ចាត់ថ្នាក់ជាសាធារណៈ ដោយមិនមានការកោសលុប)។ ឯកសារមិនមែនជាច្បាប់ចម្លងទេ ប៉ុន្តែជាទំរង់បែបបទដែលបានដាក់ដោយបុគ្គលដដែល ស្តីពីហេតុការណ៍ដូចគ្នា និងមានព័ត៌មានផ្ទាល់ខ្លួនដូចគ្នា។

[34] សូមមើល ឧបសម្ព័ន្ធ ក ផ្នែក ៣២-៣៨។

[35] សូមមើល ឧបសម្ព័ន្ធ ក ផ្នែក ៣៨។

[36] ឧបសម្ព័ន្ធ ខ អនុស្សរណៈពីក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ផ្ញើជូនសហមេធាវីនាំមុខអន្តរជាតិ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១។

18. នាពេលនេះ អង្គការសហប្រជាជាតិ និងកម្ពុជាបានចុះកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ។ កិច្ចព្រមព្រៀងបន្ថែមនេះចែងអំពីការថែរក្សាបណ្ណសារឯកសារសាធារណៈដែលត្រូវឱ្យ "មានភាពទូលំទូលាយតាមដែលអាចធ្វើទៅបាន"[37]។

19. ក៏ប៉ុន្តែពុំមានវិធានលម្អិតនៃការចូលមើលឯកសារ ពាក់ព័ន្ធនឹងបណ្ណសារនេះនៅឡើយទេ។ ច្បាប់ជាតិស្តីពីបណ្ណសារនឹងអនុវត្តទៅលើបណ្ណសារ អ.វ.ត.ក លើកលែងតែមានការអនុម័តច្បាប់ថ្មី[38]។ ច្បាប់នេះមានកំណត់អំពីការចាត់ថ្នាក់ឯកសារជាសាធារណៈក្រោយរយៈពេលកំណត់មួយ។ ក៏ប៉ុន្តែវាគឺជាអ្វីដែលមិនច្បាស់លាស់ដែលថា បណ្ណសាររបស់ អ.វ.ត.ក នឹងត្រូវបានអនុវត្តដោយក្របខ័ណ្ឌទូទៅនេះ ជាជាងដោយគោលនយោបាយនៃការចូលមើលឯកសារ ដែលបង្កើតឡើងជាក់លាក់សម្រាប់តុលាការអន្តរជាតិផ្សេងទេ[39]។ ដោយសារពុំមានភាពច្បាស់លាស់ គេមានការលំបាកក្នុងការដោះស្រាយនូវរាល់ការពិចារណាទាំងអស់៖ ឧទាហរណ៍ គឺពុំដឹងពីការបែងចែកថានរណាអាចទទួលការអនុញ្ញាតឱ្យចូលមើលសម្ភារៈសម្ងាត់ក្នុងសំណុំរឿង ឬរយៈពេលដែលកំណត់ដោយច្បាប់ស្តីពីបណ្ណសារនឹងអនុវត្តយ៉ាងដូចម្តេច។ ក៏ប៉ុន្តែ សហមេធាវីនាំមុខយល់ថា ការងារសំខាន់ស្តីពីការកំណត់នូវព័ត៌មានរសើប ដែលមាននៅក្នុងឯកសារសំណុំរឿងទាំងនោះ មិនត្រូវពន្យារនោះទេ។ ការលើកអំណះអំណាងបន្ថែមទៀតអាច ត្រូវមាន នៅពេលក្រោយ។ សហមេធាវីនាំមុខ ក៏សូមស្នើទៅកាន់អង្គការសហប្រជាជាតិនិងប្រទេសកម្ពុជា ឱ្យមានការពិគ្រោះយោបល់ជាមួយដើម

---

[37] សេចក្តីបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំចាត់ចែងជាអន្តរកាល និងការបញ្ចប់កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ មាត្រា ៣(១) [ឧបសម្ព័ន្ធ ២]។

[38] ច្បាប់ស្តីពីបណ្ណសារ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៥ (ភាសាខ្មែរ) [ឧបសម្ព័ន្ធ ៣]។

[39] សូមមើល ឧទាហរណ៍: RSCS ការកត់ត្រា និងព័ត៌មានរសើប ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ការកែប្រែនៅក្នុងការធ្វើចំណាត់ប្រភេទឯកសារ ការដោះស្រាយ និងគោលនយោបាយដែលអាចទទួលបាន ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៤។ MICT_ គោលនយោបាយដែលអាចទទួលបានសម្រាប់ការកត់ត្រា ដែលបានរក្សាទុកដោយយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦។ សូមមើលផងដែរ ព្រឹត្តិប័ត្ររបស់លោកអគ្គលេខាធិការ តុលាការព្រហ្មទណ្ឌអន្តរជាតិ: ព័ត៌មានរសើប ការធ្វើចំណាត់ប្រភេទឯកសារ ការដោះស្រាយ និងសិទ្ធិចូលមើលឯកសារ ឯកសារ ST/SGB/2012/3 ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២។

បណ្តឹងរដ្ឋប្បវេណី ក្នុងការរៀបចំនូវគោលនយោបាយឬច្បាប់ជាក់លាក់ណាមួយដែលទាក់ទងទៅនឹងការចូលមើលឯកសារ ដោយសារតែពួកគាត់ជាអ្នកដែលត្រូវទទួលការប៉ះពាល់ជាងគេក្នុងរឿងនេះ។

## ៣. គោលការណ៍គតិយុត្តិជាធរមាន

### *៣.១ គោលការណ៍ទូលំទូលាយ*

20. អត្ថបទគតិយុត្តិរបស់ អ.វ.ត.ក ចែងថា កិច្ចដំណើរការនីតិវិធីត្រូវធ្វើជាសាធារណៈ និងមានតម្លាភាព[40]។ ចំណុចនេះស្របទៅនឹងបទដ្ឋានអន្តរជាតិ ដែលបានបញ្ជាក់ច្បាស់ដែលថា សវនាការជាសាធារណៈសំដៅដល់ការដែលសាធារណជនអាចចូលមើលកំណត់ហេតុលាយលក្ខណ៍អក្សរ រួមទាំងភស្តុតាង[41]។ ដើមបណ្តឹងរដ្ឋប្បវេណីតែងតែអំពាវនាវ ឱ្យមានតម្លាភាពនិងឱ្យមានការទទួលស្គាល់ជាសាធារណៈនូវការពិតអំពីឧក្រិដ្ឋកម្មនានា ដែលស្ថិតក្រោមអំណាចការងាររបស់តុលាការ។ ចំណុចទាំងពីរនេះត្រូវតែសម្របសម្រួល ដោយអនុញ្ញាតឱ្យសាធារណជនអាចចូលមើលព័ត៌មាននានាដែលមានក្នុងសំណុំរឿង។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះនេះបានរម្លឹកថា៖

> "ការចែកចាយឱ្យបានទូលំទូលាយនូវសម្ភារពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខតុលាការ [...] គឺស្របទៅនឹងអាណត្តិរបស់ អ.វ.ត.ក ដែលរួមមានទាំងការចូលរួមចំណែកក្នុងការផ្សះផ្សាជាតិ និងការផ្តល់ឱ្យនូវឯកសារ ដើម្បីគាំទ្រដល់ការស្វែងរកការពិតខាងផ្នែកប្រវត្តិសាស្ត្រដ៏យូរអង្វែងមកហើយ"។ ការចែកចាយភស្តុតាងសំខាន់ៗជាច្រើនដែលមាននៅក្នុងសំណុំរឿង ០០១ អាចជំរុញឱ្យមាន "កិច្ចពិភាក្សាលើអតីតជាសា

---

[40] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់ទោសក្រោមច្បាប់ស្តីពីឧក្រិដ្ឋកម្មនៅកម្ពុជាដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ "កិច្ចព្រមព្រៀង អ.វ.ត.ក" មាត្រា ១២(២)។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៤ ថ្មី។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[41] ឧទាហរណ៍ សូមមើល មតិយោបល់ទៅទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៣២ ឯកសារ អ.ស.ប លេខ CCPR/C/GC/32 (២៣ សីហា ២០០៧) កថាខណ្ឌ ២៩។ <u>សេចក្តីប្រកាសទីក្រុងអ៊ីស្តាន់ប៊ុលស្តីពីតម្លាភាព និងដំណើរការតុលាការ</u> ឯកសារលេខ A/73/831-E/2019/56 ឧបសម្ព័ន្ធ I គោលការណ៍ទី ៦ និង <u>វិធានការសម្រាប់ការអនុវត្តសេចក្តីប្រកាសទីក្រុងអ៊ីស្តាន់ប៊ុលប្រកបដោយប្រសិទ្ធិភាព</u> ឯកសារលេខ A/73/831-E/2019/56 ឧបសម្ព័ន្ធ II គោលការណ៍ទី ៦(៣) ដែលបានសម្រេចដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច អ.ស.ប នៅក្នុងសេចក្តីសម្រេចលេខ ២០១៩/២២ <u>ការធ្វើឱ្យមានតម្លាភាពកាន់តែប្រសើរឡើងនៅក្នុងដំណើរការតុលាការ</u> ឯកសារលេខ E/RES/2019/22 ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩។

ធារណៈ និងដោយមិនមានការលាក់លៀម ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំមួយដែលជាលទ្ធផល អាចកាត់បន្ថយនូវទស្សនៈនៃការមិនទទួលស្គាល់ ការបំភ្លៃអង្គហេតុ និងការពិតដែលមានតែមួយផ្នែកនោះបាន"[42]។

21. ក៏ប៉ុន្តែ ស្របពេលជាមួយគ្នានោះ ភាពដាច់ខាតចំពោះតម្លាភាព និងការពិតក៏ត្រូវតែរក្សាឱ្យមានតុល្យភាពទល់នឹងផលប្រយោជន៍ផ្សេងទៀតផងដែរ[43]។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះបានធ្វើការសង្កេត "ថា ការធ្វើចំណាត់ថ្នាក់លើឯកសារត្រូវធ្វើឡើងដោយធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងតម្រូវការនៃការរក្សាការសម្ងាត់ និងតម្រូវការនៃតម្លាភាព"[44] ហើយថា "ការសម្ងាត់ចំពោះសំអាងមួយចំនួន អាចនៅតែរក្សាទុក"[45]។ បទដ្ឋានអន្តរជាតិដែលតម្រូវឱ្យមានតម្លាភាពក៏អំពាវនាវឱ្យមានករណីលើកលែងដើម្បីការពារឯកជនភាព[46] ដែលជាសិទ្ធិមួយត្រូវបានទទួលស្គាល់ក្រោមច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់តំបន់[47]។ ឧទាហរណ៍ សេចក្តីប្រកាសស្តីពីគោលការណ៍ជា

---

[42] សំណុំរឿង **០០១** ឯកសារ **F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៥។ យោងសំណុំរឿង **០០១** ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៧០៨។

[43] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ១.២។

[44] សំណុំរឿង **០០១** ឯកសារ **F30/2** សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៥។

[45] *ដូចខាងលើ* កថាខណ្ឌ ៦។

[46] ឧទាហរណ៍ សូមមើលៈ MICT គោលនយោបាយដែលអាចទទួលបានសម្រាប់ការកត់ត្រាដែលបានរក្សាទុកដោយយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ មាត្រា ៧(២) ("ក្នុងការពិចារណាអំពីលទ្ធភាពដែលអាចចូលមើលឯកសារបាន គោលការណ៍ទូទៅនៃភាពបើកចំហ និងតម្លាភាព ត្រូវតែថ្លឹមថ្លែងគ្នាជាមួយនឹងកាតព្វកិច្ចក្នុងការរក្សាភាពសម្ងាត់នៃការកត់ត្រា និងព័ត៌មានដែលបានធ្វើចំណាត់ថ្នាក់ ដើម្បីជាប្រយោជន៍នៃការទប់ស្កាត់កុំឱ្យមានព្យសនកម្ម និងការខូចខាតដល់អង្គការសហបប្រជាជាតិ ឬព្យសនកម្ម ការខូចខាត ឬការរំលោភបំពានលើភាពឯកជនរបស់បុគ្គលទាំងឡាយ")។ វិធានការសម្រាប់ការអនុវត្តសេចក្តីប្រកាសទីក្រុងអ៊ីស្តាន់ប៊ុលប្រកបដោយប្រសិទ្ធិភាព ឯកសារលេខ A/73/831-E/2019/56 ឧបសម្ពន្ធ II គោលការណ៍ទី ៦(៣) ដែលបានសម្រេចដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច អ.ស.ប នៅក្នុងសេចក្តីសម្រេចលេខ ២០១៩/២២ ការធ្វើឱ្យមានតម្លាភាពកាន់តែប្រសើរឡើងនៅក្នុងដំណើរការតុលាការ ឯកសារលេខ E/RES/2019/22 ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩។ សូមមើលផងដែរ កម្រងឯកសារច្បាប់ដែលបានយោងក្នុងជើងទំព័រ ៩៣-៩៦ ខាងក្រោម។

[47] ឯកសារជាប់ពាក់ព័ន្ធបំផុតសម្រាប់ប្រទេសកម្ពុជាៈ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ១២។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ មាត្រា ១៧។ សេចក្តីប្រកាសអំពីសិទ្ធិមនុស្សអាស៊ាន មាត្រា ២១។ គណៈកម្មាធិការសិទ្ធិមនុស្សបានពន្យល់ថា សិទ្ធិតម្រូវឱ្យ "បណ្តារដ្ឋចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីធានាថា ព័ត៌មានទាក់ទងនឹងជីវិតឯកជនរបស់បុគ្គលណាម្នាក់ មិនត្រូវធ្លាក់ចូលក្នុងដៃបុគ្គលដទៃ ដែលច្បាប់មិនបានអនុញ្ញាតឱ្យទទួល ចាត់ចែង និងប្រើប្រាស់

មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាចចែងថា ដំណើរការតាមផ្លូវតុលាការគួរ

> "ចាត់វិធានការកាត់បន្ថយភាពមិនងាយស្រួលដល់ជនរងគ្រោះ ការពារឯកជនភាពរបស់ពួកគេក្នុងករណីចាំបាច់ និងធានាសុវត្ថិភាពដល់ពួកគេ ព្រមទាំងឯកជនភាពរបស់ក្រុមគ្រួសារពួកគេ និងសាក្សីនានាក្នុងនាមពួកគេ ឱ្យចៀសផុតពីការបំភិតបំភ័យ និងការសងសឹក"[48]។

## *៣.២ ក្របខណ្ឌគតិយុត្តិជាក់លាក់*

22. គន្លឹះអត្ថបទគតិយុត្តិ អ.វ.ត.ក ដកស្រង់គោលការណ៍ទូលំទូលាយទាំងនេះ បង្កើតជាក្របខណ្ឌជាក់លាក់គឺ សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ។ មាត្រា ១២.២ ចែងថា "ការិយាល័យតុលាការចុងក្រោយដែលទទួលបានសំណុំរឿងត្រូវធ្វើការពិនិត្យឡើងវិញចំពោះឯកសារ ស្តីពីសុវត្ថិភាពនៃការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញ នៅក្នុងសំណុំរឿង" ហើយថា

> "ក. ឯកសារដែលនៅតែសម្ងាត់ ឬសម្ងាត់បំផុត ត្រូវតែពិនិត្យឡើងវិញ និងត្រូវដាក់ចំណាត់ថ្នាក់ឡើងវិញក្នុងករណីចាំបាច់។
>
> ខ. ឯកសារដែលមានផ្នែកខ្លះដែលសម្ងាត់មានកម្រិត ត្រូវធ្វើការកោសលុបឱ្យបានត្រឹមត្រូវ ក្នុងការបង្កើតនូវសំណៅថ្មីមួយទៀត។
>
> គ. បញ្ជីនៃឯកសារដែលត្រូវបានធ្វើចំណាត់ថ្នាក់ ត្រូវដាក់ចូលក្នុងសំណុំរឿង។
>
> ឃ. ឯកសារណាដែលមានត្រាក្នុងដំណាក់កាលណាមួយនៃរឿងក្តី ត្រូវធ្វើការពិនិត្យឡើងវិញ និងដែលពុំចាំបាច់មានការបោះត្រា"។

23. ទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះនេះបានទទួលស្គាល់ថា ភាគីគួរមានឱកាសបញ្ចេញមតិយោបល់ស្តីពីបញ្ហានៃការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ[49]។

---

ព័ត៌មាននេះនោះទេ ហើយមិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដែលមិនស្របនឹងកតិកាសញ្ញានេះឡើយ")។ គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ១៦៖ មាត្រា ១៧ (សិទ្ធិទទួលបានភាពឯកជន) សិទ្ធិគោរពដល់ភាពឯកជន ក្រុមគ្រួសារ និងការប្រាស្រ័យទាក់ទង និងការការពារសេចក្តីថ្លៃថ្នូរ និងកិត្តិយស ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៨៨ កថាខណ្ឌ ១០។

[48] សេចក្តីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ ៤០/៣៤ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ កថាខណ្ឌ ៦(ឃ)។

[49] ឯកសារ **E467/6** ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងជា ឯកសារសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ២។ សំណុំរឿង **001** ឯកសារ **F30** កថាខណ្ឌ ១-២, ៥។ សំណុំរឿង **001** ឯកសារ

24. សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ ក៏កំណត់នូវគោលការណ៍ពាក់ព័ន្ធនានាដែលអាចអនុវត្តបាន ដើម្បីធ្វើចំណាត់ប្រភេទឱ្យបានត្រឹមត្រូវចំពោះសម្ភារនានាដែរ។

25. មាត្រា ៤ ចែងអំពីប្រភេទសម្ភារនានាក្នុងសំណុំរឿងដែលសន្មតថាជាឯកសារសាធារណៈ។ សម្រាប់គោលបំណងនាពេលនេះ អ្វីដែលគួរឱ្យកត់សម្គាល់ជាងគេ គឺចំណុច “ភស្តុតាងដែលរួមមានរបាយការណ៍ជំនាញ ដែលត្រូវបានទទួលយកនៅក្នុងពេលជំនុំជម្រះ” (មាត្រា ៤(ឃ))។

26. ផ្ទុយទៅវិញ ប្រភេទសម្ភារមួយចំនួនត្រូវបានសន្មតថាសម្ងាត់ ឬសម្ងាត់បំផុត។ សម្ភារទាំងនេះមានរៀបរាប់នៅក្នុងមាត្រា ៥ និង ៦។ សម្ភារសម្ងាត់រួមមាន “បណ្ដឹងរបស់ជនរងគ្រោះ” (មាត្រា ៥.១(ឃ)) និង “អត្តសញ្ញាណ និងអាសយដ្ឋានលម្អិតរបស់ជនរងគ្រោះ ដែលមិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណី (ដែលរួមមានពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី)” (មាត្រា ៥.១(ង))។ សម្ភារសម្ងាត់បំផុតរួមមានព័ត៌មានពាក់ព័ន្ធនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ (មាត្រា ៦(គ)) និងសម្ភារនានាដែលស្ថិតក្រោមវិធានការការពារ (មាត្រា ៦(ខ))។

27. មាត្រា ៧ ចែងបន្ថែមអំពីការណែនាំមួយចំនួនទាក់ទិននឹងការការពារពាក់ព័ន្ធដល់សាក្សី និងជនរងគ្រោះ រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណី៖ មាត្រា ៧.២ ចែងថា៖

> អនុលោមតាមមាត្រា ៥(ង) [*sic*[50]] ពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវដាក់នៅក្នុងផ្នែកសម្ងាត់នៃសំណុំរឿង។ នៅពេលពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះត្រូវបានបដិសេធ តែមិនទាន់បានផ្សព្វផ្សាយជាសាធារណៈនៅឡើយ ពាក្យបណ្ដឹងនេះ និងសេចក្ដីលម្អិតអំពីអត្តសញ្ញាណអ្នកប្ដឹង តាមវិធាននេះ ត្រូវស្ថិតនៅក្នុងផ្នែកសម្ងាត់នៃសំណុំរឿង។

28. មាត្រា ៧.៤ ចែងថា “ព័ត៌មានលម្អិតសម្រាប់ការទំនាក់ទំនងរបស់ម្ចាស់បណ្ដឹង និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមាននៅក្នុងទម្រង់បែបបទព័ត៌មានរបស់ជនរងគ្រោះ ហើយដែលក្លាយជាសាធារណៈ ដោយអនុលោមតាមមាត្រា ៤ ត្រូវកោសលុបចេញពីឯកសារដែលយកមកដាក់ក្នុងគេហទំព័ររបស់ អ.វ.ត.ក”។

---

**F30/2** សេចក្ដីសម្រេចលើគោលការណ៍ណែនាំស្ដីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ២, ៨។

[50] មើលទៅបំណងគឺចង់យោងទៅមាត្រា ៥.១(ង) ទេ។

29. សហមេធាវីនាំមុខយល់ថា ផែនការនេះមានន័យថា ភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តីណាមួយ គួរតែចាត់ទុកជាឯកសារសាធារណៈ លើកលែងតែសម្ភារទាំងនោះមានលក្ខណៈសម្ងាត់ ឬសម្ងាត់បំផុត។ ហេតុនេះ ឯកសារដែលមានសម្ភារៈនានាដែលបានរៀបរាប់នៅក្នុងមាត្រា ៥, ៦ និង ៧ ដែលមានស្ថានភាពជាឯកសារសម្ងាត់ ឬសម្ងាត់បំផុត ត្រូវកោសលុបចេញពីឯកសារដែលត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ។

30. ទាក់ទិននឹងបញ្ហាដែលថា "ភស្តុតាង" មានអ្វីខ្លះ ទៅតាមអត្ថន័យនៃមាត្រា ៩(ឃ) នៃសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញនោះ សហមេធាវីនាំមុខកត់សម្គាល់ដល់វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដែលចែងថា "អង្គជំនុំជម្រះសាលាដំបូងសម្រេច ដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី ។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬ ភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬ ត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ ..."។ ភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ ត្រូវបានកំណត់អត្តសញ្ញាណរួចហើយ ដោយសារអង្គជំនុំជម្រះបានបង្កើតជាឯកសារលេខ E3 នៅក្នុងសំណុំរឿង[51]។

[51] "ការដាក់លេខ E3 បញ្ជាក់ថាឯកសារមួយត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬចំពោះមុខភាគីដោយពុំមានការជំទាស់នោះទេ (ឬក្នុងករណីដែលមានការជំទាស់ទៅនឹងឯកសារណាមួយ តែការជំទាស់នោះត្រូវបានអង្គជំនុំជម្រះបដិសេធ)។ ដោយអនុលោមតាមវិធាន ៨៧ (២) និងវិធាន ៨៧ (៣) អង្គជំនុំជម្រះអាចធ្វើសេចក្តីសម្រេចរបស់ខ្លួន ដោយផ្អែកលើឯកសារនានាដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី (ដូចជា "ខ្លឹមសាររបស់ឯកសារទាំងនោះត្រូវបានសង្ខេប អាន ឬបង្ហាញអត្តសញ្ញាណសមស្របនៅក្នុងតុលាការ") "ដែលត្រូវឆ្លងកាត់ការដេញដោល" និងពុំត្រូវបានដកចេញនូវហេតុផលណាមួយ ក្នុងចំណោមហេតុផលទាំង៥ ដែលមានចែងក្នុងវិធាន ៨៧ (៣) (ក) ដល់ (ង) ឡើយ។ អង្គជំនុំជម្រះ ចាត់ទុកថា ឯកសារបានឆ្លងកាត់ការដេញដោលរួចហើយ ប្រសិនបើឱកាសគ្រប់គ្រាន់ត្រូវបានផ្តល់ដល់ភាគី ដើម្បីជំទាស់ទៅនឹងការយកឯកសារនេះមកប្រើប្រាស់ ទោះបីភាគីប្រើ ឬពុំប្រើប្រាស់ឱកាសនេះក៏ដោយ។ ឯកសារថ្មីៗដែលអង្គជំនុំជម្រះយល់ថាបានបំពេញលក្ខខណ្ឌ ដូចមានក្នុងវិធាន៨៧ (៤) នៃវិធានផ្ទៃក្នុង ក៏ត្រូវបានដាក់លេខ E3 ផងដែរ។ ការដាក់លេខ E3 ត្រូវបានកត់ត្រាដោយក្រឡាបញ្ជីនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការ នីតិវិធី សម្រាប់ថ្ងៃនីមួយៗនៃសវនាការ ហើយក៏នឹងត្រូវបានជូនដំណឹងនាពេលឆាប់ៗទៅភាគី តាមរយៈកម្មវិធីឯកសារស្តីពីសវនាការប្រចាំថ្ងៃ (Daily Trial Documents interface)។ នៅពេលត្រូវបានដាក់លេខ E3 រួចហើយ ឯកសារដែលមានលេខ នឹងជំនួសលេខ E3 ឯកសារមុនៗដែលធ្លាប់ត្រូវបានដាក់ឱ្យឯកសារនោះ។" សូមមើល ឯកសារលេខ **E178/1** ចំណងជើង "សំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំបញ្ជាក់អំពីប្រភេទនៃឯក

### *៣.៣ ចំណុចមិនច្បាស់លាស់*

31. ទោះបីជាមានក្របខណ្ឌនេះក៏ដោយ ចំណុចនៃភាពមិនច្បាស់លាស់នៅតែមាន ជាពិសេស ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋាននេះតែម្ដង៖

(ក) សេចក្ដីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ មិនមានភាពច្បាស់លាស់ថាតើ មាត្រា ៥ មាត្រា ៦ និងមាត្រា ៧ មានបំណងផ្ដល់បញ្ជីនៃសំភារៈ*ទាំងអស់* ដែលគួរត្រូវបានលើកលែងពីឋានៈជាសាធារណៈ ឬថាតើ ចៅក្រម និងអង្គជំនុំជម្រះ នៅតែមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាសំភារៈផ្សេងទៀតជា សំភារៈសម្ងាត់។ ប្រសិនបើចៅក្រមមានឆន្ទានុសិទ្ធិបន្តរក្សាការសម្ងាត់នៃឯកសារសំណុំរឿងផ្សេងទៀតនោះ វាមិនច្បាស់ថាតើប្រភេទសំភារៈណាមួយដែលអាចនឹងយកមកប្រើប្រាស់ដើម្បីការពារ។

(ខ) វាមិនច្បាស់ថាតើការធ្វើចំណាត់ថ្នាក់ឯកសារអ្វីចំពោះសំភារៈទាំងឡាយ ដែលមិនស្ថិតនៅក្រោមក្របខ័ណ្ឌនៃមាត្រា ៤, ៥, ៦, ឬ ៧។

32. ការធ្វើចំណាត់ថ្នាក់មិនស៊ីសង្វាក់គ្នា និងការកោសលុបឯកសារដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ ដូចបានលើកឡើងក្នុងកថាខណ្ឌ ១៦ ខាងលើ បង្ហាញអំពីកង្វះនៃក្របខណ្ឌច្បាស់លាស់ដែលអាចអនុវត្តបាន និងបង្ហាញអំពីរបៀបដែលវាអាចប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាពិសេសនៅពេលដែលពួកគាត់មិនបានទទួលឱកាសក្នុងការបញ្ចេញមតិយោបល់។

33. ផ្នែកខាងក្រោមនៃសេចក្ដីសន្និដ្ឋានទាំងនេះ បង្ហាញនូវទិដ្ឋភាពទូទៅនៃសំភារៈសំណុំរឿង ០០២ ទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្ដោតជាពិសេសលើសំភារៈដែលរងផលប៉ះពាល់ដោយសារចំណុចនៃភាពមិនច្បាស់លាស់ទាំងនេះ។

## ៤. សំភារៈដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង

---

សារ E3 ជាក់លាក់មួយចំនួន (ឯកសារ E178) និងសំណើសុំ E167" ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ២។ សូមមើលផងដែរ ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ៤៤។ ឯកសារលេខ **E190** សេចក្ដីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ១៨។ ឯកសារលេខ **E305/17** សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារទាំងឡាយដែលបានស្នើដាក់ នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង០០២/០២ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ២៧។

*៤.១ ទិដ្ឋភាពទូទៅនៃសំភារៈដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង*

34. ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗក្នុងក្រុមរួម[52] បានដាក់ទម្រង់បែបបព័ត៌មានអំពីជនរងគ្រោះ ដើម្បីចូលរួមក្នុងសំណុំរឿង ០០២។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានដាក់ទម្រង់បែបបទអំពីព័ត៌មានបន្ថែមលើទម្រង់បែបបព័ត៌មានអំពីជនរងគ្រោះរបស់ពួកគេ ដោយរៀបរាប់លម្អិតអំពីទិដ្ឋភាពជាក់ស្តែងបន្ថែមនៃឧក្រិដ្ឋកម្មដែលពួកគេបានជួបប្រទះ និង/ឬព្យសនកម្មដែលពួកគេបានទទួលរង។[53] ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២ មួយចំនួន បានដាក់ទម្រង់បែបបព័ត៌មានអំពីជនរងគ្រោះ និងទម្រង់បែបបទអំពីព័ត៌មានបន្ថែមក្នុងសំណុំរឿង ០០៣ និង/ឬ ០០៤ ដែលជាលទ្ធផលនៃកាបង្ហាញព័ត៌មានទាំងនេះ ក៏ឃើញមាននៅក្នុងសំណុំរឿង ០០២ ផងដែរ។[54] ដើមបណ្តឹងរដ្ឋប្បវេណីក៏បានផ្តល់ការសម្ភាសជូន ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ជាលទ្ធផល សំណុំរឿងនេះរួមមានកំណត់ហេតុនៃការស្តាប់ចម្លើយពីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានផ្តល់ការសម្ភាសដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបានបញ្ចូលក្នុងសំណុំរឿងផងដែរ។ សំណុំរឿងក៏មានឯកសាររដ្ឋបាលពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងរបាយការណ៍នៃអង្គភាពគាំពារជនរងគ្រោះ (“VSS”[55]) ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លិខិតតំណាងដោយអាណត្តិ និងឯកសារទាក់ទងនឹងសំណើសុំ

---

[52] បច្ចុប្បន្ននេះ បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣៨៦៥នាក់។ លើសពីនេះ បុគ្គលពីររូបដែលកន្លងមកមានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី បានដកខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប បានទទួលមរណភាព ដោយមានលិខិតបញ្ជាក់ពីមរណភាពនៅក្នុងសំណុំរឿង ប៉ុន្តែមិនមានការទាមទារសំណងរបស់អ្នកស្នងទេ។ ឯកសារសម្រាប់បុគ្គលទាំងនេះ មាននៅក្នុងសំណុំរឿងនៅឡើយ។ សំណុំរឿង ក៏មានឯកសារពីបុគ្គលដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមិនត្រូវបានទទួលយក។

[53] ឯកសារគោលដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅត្រូវបានផ្តល់លេខសំណុំរឿងដែលនៅក្នុងសំណុំរឿង០០២ ចាប់ផ្តើមដោយ D22 ហើយភ្ជាប់ទៅលេខតែមួយគត់របស់បណ្តឹងរដ្ឋប្បវេណីនីមួយៗ។ បញ្ជីដើមបណ្តឹងរដ្ឋប្បវេណីមាននៅក្នុងឧបសម្ព័ន្ធទី II ភ្ជាប់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (**E465.3**) កំណត់លេខ D22 របស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ។ ឯកសារទាំងនេះត្រូវទទួលយកបន្តបន្ទាប់ជាភស្តុតាងត្រូវបានប្តូរលេខទៅជាលេខ E3 ។ជួនកាលប៉ុន្តែមិនរហូតត តំណភ្ជាប់រវាងលេខ E3 និងលេខ D22 បង្ហាញពីការប្រើប្រាស់ឯកសារជំនួសនៅក្នុងសំណុំរឿងជំនួសឯកសារដើម D22។

[54] ឯកសារបន្ទាប់ ជាមួយសម្ភារៈផ្សេងទៀតដែលបានមកពីសំណុំរឿងដទៃទៀត ត្រូវបានផ្តល់លេខក្នុងសំណុំរឿង ០០២ ដែលចាប់ផ្តើមដោយ E319 (លុះត្រាតែ បានទទួលយកជាភស្តុតាង និងផ្តល់លេខជា E3)។

[55] ជាទូទៅ នៅក្នុង Zylab មានចំណងជើង “របាយការណ៍អង្គភាពជនរងគ្រោះស្តីពី... ឬ “របាយការណ៍របស់អង្គភាពជនរងគ្រោះ ស្តីពី...”។

បន្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី។[56] ឯកសារទាំងនេះ ជារួម បង្កើតបានជាសំណុំសំភារៈដើមបណ្តឹងរដ្ឋប្បវេណីរួមនៅក្នុងសំណុំរឿង។

35. ក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំត្រូវបានទទួលយកជាភស្តុតាង។ ករណីដែលកើតឡើង លេខដំបូងដែលផ្តល់ឱ្យត្រូវជំនួសដោយ E3។ ឯកសារដែលបានទទួលយកជាភស្តុតាងនិងបានកំណត់ជាឯកសារ E3 ក្នុងនោះរាប់បញ្ចូលទាំងឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មនៅក្នុងពីរពីរវគ្គ ប៉ុន្តែរួមទាំងចំនួនឯកសារ ច្រើនផ្សេងទៀតផងដែរ ដែលត្រូវបានស្នើឡើងជាភស្តុតាងបានៅក្នុងបញ្ជីរបស់ភាគី ឬត្រូវបានយោងនៅក្នុងសវនាការ។ សហមេធាវីនាំមុខបានប៉ាន់ស្មានថា ភស្តុតាង (ឯកសារ E3) ក្នុងសំណុំរឿង ០០២ មានទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះជាង ៣០០០ និងទម្រង់បែបបទអំពីព័ត៌មានបន្ថែមជាង ១០០០[57]។ ឯកសារ E3 ក៏មានឯកសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនផ្សេងទៀត ដូចជាកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា កំណត់ហេតុនៃការស្តាប់ចម្លើយ និងកំណត់ហេតុផ្សេងទៀត ដែលផលិតដោយ ក.ស.ច.ស។

36. សំណុំរឿងនេះមានឯកសារមួយចំនួនច្រើជាងនេះទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែល*មិនត្រូវបាន*ដាក់បញ្ចូលជាភស្តុតាងនៅក្នុងការជំនុំជម្រះណាមួយក្នុងចំណោមការជំនុំជម្រះទាំងពីរ។ ភាគច្រើននៃទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងទម្រង់បែបបទអំពីព័ត៌មានបន្ថែម (តាមការប៉ាន់ស្មាន មានឯកសារចំនួន ១៤៤០០) មិនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជាភស្តុតាងនោះទេ ហើយនៅតែមានលើសំណុំរឿង ទាំងលេខឯកសារដើម "លេខ D22" ឬក្នុងករណីខ្លះមានលេខសម្គាល់ផ្តើមដោយ E319 ដែលឯកសារទាំងនោះត្រូវបានបង្ហាញជាសាធារណៈពីសំណុំរឿង។ នៅក្នុងសំណុំរឿងដដែលតាំងពីអំឡុងពេលនៃកិច្ចស៊ើបសួរមកម្លេះ។ ដូចគ្នានេះដែរ ឯកសាររដ្ឋបាលភាគច្រើនទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងរបាយការណ៍នៃអង្គភាពគាំពារជនរងគ្រោះ លិខិតតំណាងដោយអាណត្តិ និងការទាមទារសំណងរបស់សិទ្ធិវ័ន្តមិនត្រូវបានដាក់បញ្ចូលជា

[56] ឯកសាររដ្ឋបាលទាំងនេះត្រូវបានផ្តល់លេខ D22 ឬលេខដែលចាប់ផ្តើមដោយ E2 (លុះត្រាតែត្រូវបានទទួលយកជាភស្តុតាង និងត្រូវបានផ្តល់លេខ E3)។

[57] ទូរលេខដែលបានផ្តល់ក្នុងសារណានេះ គឺរាប់បញ្ចូលគ្រប់ភាសានៃឯកសារជាឯកសារមួយដោយឡែក។ ដូច្នេះទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះដែលមានក្នុងសំណុំរឿងជាភាសាខ្មែរ អង់គ្លេស និងបារាំងត្រូវបានរាប់ជា៣ឯកសារ។

ភស្តុតាងនោះទេ (ទោះបីជាវាបង្ហាញថា ឯកសារទាំងនេះមួយចំនួនតូចត្រូវបានទទួលយកជាភស្តុតាងនិងត្រូវបានផ្តល់លេខសម្គាល់ E3 រួចហើយក៏ដោយ)។

## *៤.២ សំភារៈឯកជន និងរសើបពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី*

37. ឯកសារជាច្រើនដែលបានពិពណ៌នាខាងលើរួមមានព័ត៌មានអំពីដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចមិនសមស្របក្នុងការចេញផ្សាយជាសាធារណៈ។ ទោះបីជាអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណីមានជាសាធារណៈរួចហើយក៏ដោយ[58] ឯកសារដែលដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនមានផ្ទុកនូវព័ត៌មានឯកជនយ៉ាងច្រើនលើសពីនេះទៅទៀត។ ការយល់ឃើញរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីរបៀបដែលត្រូវចាត់ចែងព័ត៌មានបែបនេះ គឺមិនមានដូចគ្នាទេ៖ ក្នុងចំណោមការពិគ្រោះយោបល់លើសំណួរនេះកន្លងមកមានចំនួនកម្រិត[59] អ្នកខ្លះមិនមានការព្រួយបារម្ភ អំពីការផ្សព្វផ្សាយលើប្រភេទព័ត៌មានពិសេសរបស់ខ្លួននោះទេ ប៉ុន្តែអ្នកផ្សេងទៀតបានសម្តែងការព្រួយបារម្ភអំពីព័ត៌មានមួយប្រភេទ ឬច្រើនប្រភេទដែលការផ្សព្វផ្សាយនេះអាចបង្កគ្រោះថ្នាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដទៃ។ ការព្រួយបារម្ភ មានទៅលើប្រភេទព័ត៌មានដូចខាងក្រោម៖

38. *ព័ត៌មានទំនាក់ទំនងលម្អិត៖* ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ ទម្រង់ព័ត៌មានបន្ថែមនិងឯកសារដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ជាធម្មតាមានព័ត៌មានទំនាក់ទំនង ដូចជា អាសយដ្ឋាននិងលេខទូរស័ព្ទរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ហើយក្នុងករណីខ្លះ អាសយដ្ឋានអ៊ីមែល)។ មានទាំងច្បាប់ថតចម្លងនៃឯកសារអត្តសញ្ញាណផ្ទាល់ខ្លួន (រួមទាំងរូបថត) ឬយ៉ាងហោចណាស់លេខអត្តសញ្ញាណដែលបានពីឯកសារបែបនេះ។ ព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតដូចជា ថ្ងៃខែឆ្នាំកំណើត និងព័ត៌មានលម្អិតអំពីសមាជិកគ្រួសារក៏ត្រូវបានរួមបញ្ចូលជាញឹកញាប់ផងដែរ។ សារៈសំខាន់នៃការការពារព័ត៌មានបែបនេះត្រូវបានឆ្លុះបញ្ចាំងរួចហើយនៅក្នុងសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ (សូមមើលផ្នែក ៣.២ ខាងលើ)។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានសម្តែងការ

---

[58] ឯកសារលេខ **E465.2** ឧបសម្ព័ន្ធ II នៃសាលក្រម ជាបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី។

[59] សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពឹងផ្អែកលើមូលនិធិពីម្ចាស់ជំនួយពីខាងក្រៅ ដើម្បីគាំទ្រការចូលរួមរបស់ពួកគេជាមួយដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះថវិកាសម្រាប់ការងារនេះមិនត្រូវបានផ្តល់ដោយការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក។ មូលនិធិម្ចាស់ជំនួយដែលអាចរកបាននៅពេលនេះគឺមានកំណត់ ដូច្នេះវាមានការដាក់កម្រិតសមត្ថភាពរបស់សហមេធាវីនាំមុខក្នុងការស្វែងរកទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុងលើបញ្ហាទាំងនេះ និងសំណួរសំខាន់ៗផ្សេងទៀត។

ព្រួយបារម្ភថា ប្រសិនបើព័ត៌មានលម្អិតបែបនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ពួកគេអាចប្រឈមនឹងការរុករានពីជនខិលខូច តាមទូរស័ព្ទ ឬការបោកប្រាស់តាមអ៊ីនធឺណែត។

39. *ព័ត៌មានកំណត់អត្តសញ្ញាណជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ៖*[60] ឯកសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំកំណត់អត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរៀបរាប់រឿងរ៉ាវជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ឬឈ្មោះខ្លះ និង/ឬ មិនដូច្នោះទេនោះ កំណត់អត្តសញ្ញាណជនទីបីថាជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ[61]។ ព័ត៌មាននេះ ប្រសិនបើផ្សព្វផ្សាយជាសាធារណៈ អាចបណ្តាលឱ្យមានផលវិបាកអវិជ្ជមានមកលើបុគ្គលទាំងនេះ ប្រសិនបើស្វាមី កូន សាច់ញាតិគ្រួសារ ឬសហគមន៍របស់ពួកគេមិនបានដឹងអំពីព័ត៌មានដែលចោទជាបញ្ហានេះ។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លះបានលើកឡើងអំពីការមានកូនកើតចេញពីការរំលោភសេពសន្ថវៈ[62] ដែលបញ្ហានេះអាចកូន ប្តី ឬ ក្រុមគ្រួសារ

[60] សហមេធាវីនាំមុខសង្កត់ធ្ងន់ថា ផ្នែកនេះគឺធំជាងករណីនៃការរួមភេទដោយបង្ខំនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២។ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំនិយាយអំពីលក្ខណៈនៃអំពើហិង្សាផ្លូវភេទផ្សេងទៀតដែលកើតឡើងនៅខាងក្រៅអាពាហ៍ពិពាហ៍។

[61] សូមមើលឧទាហរណ៍៖ ឧបសម្ព័ន្ធ ក ផ្នែក ៣៩ (ដែលរៀបរាប់ពីការរំលោភជាប្រព័ន្ធលើនារីវៀតណាមនៅក្នុងភូមិមួយដែលបានផ្តល់ឈ្មោះ និងផ្តល់ឈ្មោះ អាសយដ្ឋានបច្ចុប្បន្ន និងឈ្មោះរបស់សមាជិកគ្រួសារដែលបានកំណត់អត្តសញ្ញាណជនជនរងគ្រោះចំនួនប្រាំនាក់) ឧបសម្ព័ន្ធ ក ផ្នែក ៤០ (ដែលរៀបរាប់ពីឈ្មោះសមាជិកគ្រួសារដែលត្រូវបានរំលោភនិងសម្លាប់) ឧបសម្ព័ន្ធ ក ផ្នែក ៤១ (ដែលរៀបរាប់ពីឈ្មោះស្ត្រីម្នាក់ និងពត៌មានអំពីភូមិដែលគាត់មានទីលំនៅ ដែលត្រូវបានរំលោភនិងបំពានផ្លូវភេទ។ ឧបសម្ព័ន្ធ ក ផ្នែក ៤២ និង ៤៣ (ដែលរាប់បញ្ចូលទាំងព័ត៌មានលម្អិតនៃការរំលោភ និងការបំពានផ្លូវភេទរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាលទ្ធផល គាត់មានផ្ទៃពោះ ហើយបង្កើតកូនរហូតនៅរស់រានមកដល់សព្វថ្ងៃ)។ ឧបសម្ព័ន្ធ ក ផ្នែក ៤៤ (ដែលយោងទៅលើការបំពានផ្លូវភេទ ដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី ហើយកំណត់អត្តសញ្ញាណដោយស្ត្រីម្នាក់ដែលមកពីកងចល័តជាមួយគ្នា ថាជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាអ្នកត្រូវបានប្រធានកងឈ្លបចាប់រំលោភ រហូតមានផ្ទៃពោះ ហើយត្រូវបានបង្ខំឱ្យរៀបការជាមួយជនដែលរំលោភខ្លួន ក៏ដូចជាមានឈ្មោះភូមិដែលជាទីកន្លែងដែលជនរងគ្រោះរស់នៅបច្ចុប្បន្នជាមួយកូនរបស់ខ្លួន) ឧបសម្ព័ន្ធ ក ផ្នែក ៤៥ (ដែលរៀបរាប់អំពីការរំលោភសេវសន្ថវៈទៅលើសមាជិកគ្រួសារដែលត្រូវបានបញ្ចេញឈ្មោះ ហើយនិងរបៀបដែលគាត់ត្រូវបានគេសម្លាប់តាមរយៈការប្រើហិង្សាផ្លូវភេទ)។ ឧបសម្ព័ន្ធ ក ផ្នែក ៤៦ និង ៤៧ (ដែលរៀបរាប់ពីការឃើញផ្ទាល់ភ្នែកជនរងគ្រោះដែលស្ត្រីម្នាក់ទៀត ដែលត្រូវបានបញ្ចេញឈ្មោះ ត្រូវបានគេបំពារបំពានផ្លូវភេទ)។ ឧបសម្ព័ន្ធ ក ផ្នែក ៤៨ (ដែលជាឈ្មោះរបស់តតីយជនដែលត្រូវបានគេរំលោភ) ។

[62] សូមមើលឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ៤២ និង ៤៣ (ដែលដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់ពីខ្លួនត្រូវបានគេចាប់រំលោភដោយកងឈ្លប ហើយមានកូន រស់នៅមកទល់បច្ចុប្បន្ន)។ ឧបសម្ព័ន្ធ ក ផ្នែក ៤៤ (ដែលដើមបណ្តឹងរដ្ឋប្បវេណីបានរំលេចឈ្មោះស្ត្រីម្នាក់ដែលមានផ្ទៃពោះដោយសារការចាប់រំលោភ និងការបង្ខំឱ្យរៀបការជាមួយអ្នកដែលរំលោភខ្លួន ហើយឈ្មោះនៃទីកន្លែងដែលកើតឡើង និងកូននោះ គឺនៅរស់ នៅទីកន្លែងសព្វថ្ងៃ)។

របស់ពួកគេពុំបានដឹងនោះឡើយ ហើយអាចបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរ ប្រសិនបើកាលៈទេសៈទាំងនេះត្រូវបានលាតត្រដាង។

40. *ព័ត៌មានវេជ្ជសាស្ត្រផ្ទាល់ខ្លួន៖* ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានផ្តល់ព័ត៌មានអំពីបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្ត និង/ឬការព្យាបាលដែលខ្លួនបានទទួល។ ករណីនេះឃើញមានជាពិសេសនៅក្នុងទម្រង់បែបបទអំពីជនរងគ្រោះ ដោយសារផ្នែក គ នៃទម្រង់បែបបទ បានស្នើសុំព័ត៌មានអំពីប្រភេទនៃព្យសនកម្ម ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីបានចង្អុលបង្ហាញ ពីលក្ខខណ្ឌសុខភាពផ្លូវចិត្ត និងអាការៈដែលពួកគេបានទទួលរង តួយ៉ាង ជំងឺបាក់ស្បាត (PTSD) ជំងឺធ្លាក់ទឹកចិត្ត ឆាប់ភ័យស្លន់ស្លោ ថប់ក្នុងទ្រូង គេងមិនលក់ និងសកម្មភាពហិង្សាជាដើម[63]។ មានដើមបណ្តឹងជាច្រើនបានលាតត្រដាងការព្យាបាលដោយឱសថ ឬផ្លូវចិត្ត ដែលពួកគេបានទទួល ដោយអ្នកខ្លះបានដាក់ឈ្មោះស្ថាប័នទៀត[64]។ ក្នុងករណីខ្លះភស្តុតាងនៃជំងឺផ្លូវចិត្ត ឬការព្យាបាល បានផ្តល់ឱ្យក្នុងទម្រង់នៃលិខិតរបស់វេជ្ជបណ្ឌិត និង/ឬ កំណត់ត្រាវេជ្ជសាស្ត្រ និងការព្យាបាលលម្អិត[65]។ ឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក៏បានរៀបរាប់អំពីអាការៈនៃសុខភាពផ្លូវចិត្តដែលដើមបណ្តឹងផ្សេងដែលនៅជិតគ្នាធ្លាប់ឆ្លងកាត់[66]។ បញ្ហានៃសុខភាពផ្លូវកាយជាច្រើន ក៏ត្រូវបានរៀបរាប់ផងដែរ រួមទាំងសុខភាពខ្លះជាអ្វីដែលជាឯកជនភាព រួមមានបញ្ហារោគស្ត្រី ឬផលប៉ះពាល់ដែលឆ្លងតាមការរួមភេទ[67]។ បញ្ហាមួយចំនួនដែលបានលាតត្រដាងតាមរបៀបនេះអាចបណ្តាលឱ្យមានការមាក់ងាយ។ ប៉ុន្តែទោះបីករណីនេះមិនអាចកើតឡើងក៏ដោយ ករណីទាំងនេះនៅតែជារឿងផ្ទាល់ខ្លួន ដែលជាបញ្ហាផ្ទាល់ខ្លួន ទំនងមិនចង់បង្ហាញជាសាធារណៈ។

41. *បទពិសោធន៍ និងទស្សនៈស្តីពីអាពាហ៍ពិពាហ៍៖* នៅក្នុងសំណុំរឿង ០០២ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦៧នាក់ ត្រូវបានអនុញ្ញាតឱ្យចូលរួម ដោយផ្អែកតាមព្យសនកម្ម ដែលទទួលរងដោយសារការកំណត់បទបញ្ជាអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចបានបញ្ជាក់នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០២ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងទៀតមាន

---

[63] សូមមើលឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ៥៣, ៥៦, ៦៤។

[64] សូមមើលឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ៤៥, ៥៣, ៥៦, ៥៧, ៥៨, ៥៩, ៦២, ៦៣, ៦៤។

[65] សូមមើលឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ៥៦។

[66] សូមមើលឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ២១, ៥២។

[67] សូមមើលឧទាហរណ៍ ឧបសម្ព័ន្ធ ក ផ្នែក ៥៣, ៥៤, ៥៥។

បទពិសោធន៍ផ្សេងៗគ្នានៃអាពាហ៍ពិពាហ៍ទាំងនេះ ដោយអ្នកខ្លះនៅជាប់គ្នាជាប្ដីប្រពន្ធនៅក្រោមសម័យកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយដោយស្មោះត្រង់នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ទម្រង់បែបបទអំពីព័ត៌មានបន្ថែម និងកំណត់ហេតុនៃការស្ដាប់ចម្លើយ អំពីអារម្មណ៍របស់ពួកគេចំពោះសហព័ទ្ធ និងអំពីការរួមភេទនៅក្នុងអាពាហ៍ពិពាហ៍។ ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនមិនចង់ឱ្យប្ដីប្រពន្ធ អតីតប្ដីប្រពន្ធ កូន សាច់ញាតិគ្រួសារ ឬ សហគមន៍ដឹងពីរឿងផ្ទាល់ខ្លួនទាំងនេះទេ។

42. *សំភារៈ ដែលទទួលបានតាមរយៈទារុណកម្ម រួមទាំងចម្លើយសារភាព និងប្រវត្តិរូប៖* សំណុំរឿងមានឯកសារជាច្រើន ដែលត្រូវបានបង្កើតឡើងតាមរយៈការប្រើប្រាស់ទារុណកម្ម ឬ ការធ្វើបាប ឬ ការគំរាមកំហែង។ ទាំងនេះរួមបញ្ចូលចម្លើយសារភាពនៅមន្ទីរសន្តិសុខ ក៏ដូចជាប្រវត្តិរូបដែលត្រូវបានសរសេរឡើងក្រោមការគំរាមកំហែង។ ខ្លះមានប្រភពមកពីដើមបណ្ដឹងរដ្ឋប្បវេណី។ ឯកសារទាំងនេះច្រើនតែមានព័ត៌មានមិនពិតអំពីអ្នកសរសេរខ្លួនឯង ឬ អ្នកផ្សេងទៀតរួមទាំងសមាជិកគ្រួសារ ដែលអាចចាត់ទុកថាមានគ្រោះថ្នាក់។ សហមេធាវីនាំមុខកត់សម្គាល់ថា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងបានកំណត់គោលការណ៍រឹតបន្តឹងការពិនិត្យមើលឯកសារទាំងនេះ[68]។

43. *ការកំណត់ឈ្មោះចារីដែលត្រូវបានសង្ស័យ៖* ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនបានបញ្ជាក់ថា កម្មាភិបាលថ្នាក់ក្រោមនៅក្នុងសហគមន៍របស់ពួកគេជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ជាពិសេសនៅក្នុងទម្រង់បែបបទអំពីជនរងគ្រោះ ដោយសារតែផ្នែក ខ នៃទម្រង់បែបបទនេះ បានស្នើសុំជាពិសេសទាក់ទងនឹងការចោទប្រកាន់លើចារីនៃឧក្រិដ្ឋកម្ម ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរង។ ព័ត៌មានដូចគ្នានេះក៏ឃើញមាននៅក្នុងការពិពណ៌នារៀបរាប់នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឬ ទម្រង់បែបបទអំពីព័ត៌មានបន្ថែម ក៏ដូចជានៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយផងដែរ។ វាអាចនឹងមិនមានបញ្ហាអ្វីឡើយក្នុងការបង្ហាញការសង្ស័យទាំងនេះ (ឧទាហរណ៍ ត្រង់ចំណុចទាំងឡាយណា ដែលបានដឹងឮជាទូទៅទៅហើយ ឬ ត្រង់ចំណុចទាំងអស់ស្ដីពីមរណភាពនៃអ្នកពាក់ព័ន្ធ) ប៉ុន្តែយ៉ាងហោចណាស់ករណីខ្លះដែលបង្ហាញពីការចោទប្រកាន់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អំពីអំពើល្មើសប្រឆាំងនឹងអ្នកដទៃអាចក្លាយជាប្រភពនៃជម្លោះនៅក្នុងសហគមន៍ ឬការសងសឹក។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ជាទូទៅថា

[68] សូមមើល ចូលទៅកាន់ឯកសារ នៅលើវេបសាយសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។

ឱ្យអាជ្ញាធរមានសមត្ថកិច្ចជាអ្នកស៊ើបអង្កេតរឿងនេះចុះ ប៉ុន្តែមានការព្រួយបារម្ភអំពីការបង្ហាញវាជាសាធារណៈ។

44. ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានចូលរួមក្នុងរឿងក្តីនេះជាពិសេស ដើម្បីឱ្យបទពិសោធន៍របស់ពួកគេត្រូវបានទទួលស្គាល់ និងដឹងឮជាសាធារណៈ។ ទោះយ៉ាងណាក៏ដោយ ការលើកទឹកចិត្តនឹងមានភាពខុសប្លែកគ្នា[69]។ ដូច្នេះ វាមិនភ្ញាក់ផ្អើលឡើយដែលដើមបណ្តឹងរដ្ឋប្បវេណីមានទស្សនៈផ្សេងគ្នាទាក់ទងថាតើឯកសារ និងព័ត៌មានរសើបរបស់ពួកគាត់គួរតែត្រូវបានដាក់ជាសាធារណៈឬយ៉ាងណា។ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បានខ្នះខ្នែងចែករំលែកបទពិសោធន៍របស់ខ្លួនជាសាធារណៈ ក៏នៅមានដើមបណ្តឹងផ្សេងទៀតបានស្នើសុំឱ្យមានវិធានការការពារ[70] មិនចង់ធ្វើសក្ខីកម្មជាសាធារណៈ ឬបានបញ្ជាក់យ៉ាងជាក់លាក់អំពីការចង់ឱ្យព័ត៌មាន ឬអត្តសញ្ញាណរបស់ខ្លួន មិនឱ្យសាធារណជនបានឃើញដែរ[71]។ ពេលដែលវិធានការការពារមិនត្រូវបានផ្តល់នៅវគ្គបុរេជំនុំជម្រះ គឺដោយសារមានការចាត់ទុកថាមិនចាំបាច់ *នៅវគ្គនោះ* ដោយសារដំណើរការស៊ើបអង្កេតមិនមានលក្ខណៈសាធារណៈ[72] ដែលនេះបង្ហាញនូវសារៈសំខាន់នៃការលើកម្តងទៀតនូវបញ្ហា

---

[69] ទម្រង់ទាំងនេះ មានគោលបំណងផ្សេងៗគ្នា ហើយត្រូវបានប្រើប្រាស់ដោយបុគ្គលម្នាក់ៗក្នុងគោលបំណងផ្សេងៗគ្នា។ ចំពោះបុគ្គលខ្លះ វាជាវិធីមួយដើម្បីរាយការណ៍ព័ត៌មានទាក់ទងនឹងឧក្រិដ្ឋកម្មស្ថិតក្រោមកិច្ចស៊ើបសួរ។ សម្រាប់បុគ្គលខ្លះទៀត វាជាវិធីមួយដើម្បីបំពេញ ការទទួលស្គាល់ពីតុលាការ ឬពីសាធារណៈទាក់ទិននឹងឧក្រិដ្ឋកម្មដែលពួកគាត់បានទទួលរង។ សម្រាប់បុគ្គលផ្សេងទៀត វាគ្រាន់តែជាវិធីមួយដើម្បីទទួលបាននូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី និងសំណងសម្រាប់ព្យសនកម្មដែលបានទទួលរង។

[70] វិធានការការពារត្រូវបានស្នើក្នុងវគ្គស៊ើបអង្កេត និងក្រោយមកក្នុងវគ្គសវនាការដោយដើមបណ្តឹងរដ្ឋប្បវេណីដែលអាចត្រូវបានហៅឱ្យធ្វើសក្ខីកម្ម។

[71] សូមមើលឧទាហរណ៍ ឯកសារ **E293** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង "សេចក្តីសម្រេចលើសំណើសុំវិធានការការពារទាំងអស់នៅក្នុងសំណុំរឿង ០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និងបង្គាប់ឱ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ (ឯកសារ E286)" ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ កថាខណ្ឌ១-២។ ឯកសារ **E307/6** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧(៤) ដែលស្នើសុំទទួលយកជាភស្តុតាងនូវសក្ខីកម្មផ្ទាល់មាត់ និងឯកសារ ព្រមទាំងវត្ថុតាងដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ២២ ។ ឧបសម្ព័ន្ធ ក ផ្នែក ២២, ២៣។

[72] សូមមើលឧទាហរណ៍៖ ឯកសារ D111 [សម្ងាត់] ដីកាសម្រេចទាក់ទិននឹងវិធានការការពារ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨។ ឯកសារ D112 [សម្ងាត់] ដីការសម្រេចទាក់ទិននឹងវិធានការការពារ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៨។ ឯកសារ D405 [សម្ងាត់] ដីការសម្រេចស្តីពីវិធានការការពារ ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១០។ ឯកសារ D413 [សម្ងាត់] ដីកាសម្រេច

នេះមុនបើករឿងក្តីឱ្យមានលក្ខណៈសាធារណៈនៅវគ្គក្រោយៗមក។ ករណីនេះអាចមានការកើតឡើងស្រដៀងគ្នាផងដែរទៅលើសំណើវិធានការការពារមួយចំនួនធំ ដែលត្រូវបានដកហូតនៅវគ្គស៊ើបអង្កេត ក្រោយពីមានការពិភាក្សាជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ[73]។ ហើយបញ្ហានោះគឺថា នៅពេលទម្រង់បែបបទព័ត៌មានជនរងគ្រោះ និងឯកសារប្រហាក់ប្រហែល ត្រូវបានបំពេញ ការយល់ព្រមដាក់លាក់លម្អិតឱ្យផ្សាយខ្លឹមសារ (ឬផ្នែកខ្លះ) នោះទេ។ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនមិនបានបង្ហាញអំពីបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការអនុញ្ញាតឱ្យសាធារណៈជនប្រើប្រាស់នោះទេ។ ដោយពិចារណាឃើញថា ឯកសារទាំងនេះត្រូវបានបង្កើតឡើងដំបូងដោយមានការធ្វើចំណាត់ថ្នាក់ជាឯកសារសម្ងាត់ ដើមបណ្តឹងរដ្ឋប្បវេណី (ឬ យ៉ាងហោចណាស់ អ្នកខ្លះ) ជឿជាក់ថា ការធ្វើចំណាត់ថ្នាក់បែបនេះនឹងមិនផ្លាស់ប្តូរ។ ការដាក់បញ្ចូលនៅក្នុងឯកសារខ្លះ (ជាពិសេសឯកសារដែលបានដាក់ជូនដោយជួយពីមជ្ឈមណ្ឌលឯកសារកម្ពុជា) នៃស្តង់ដាលើកលែងទាក់ទងនឹងវិធានការការពារ និងការផ្សាយជាសាធារណៈ មិនធ្វើឱ្យមានកង្វល់ដល់ការព្រួយបារម្ភទាំងនេះទេ។ ការលើកលែងទាំងនេះ មិនឆ្លើយតបសំណួរ ថាតើឯកសារដែលបានដាក់ជាសាធារណៈ គួរមានការកោសលុបតាមជម្រើស ហើយវាមិនត្រូវបានគេដឹងទេថាតើលទ្ធភាពនេះ ត្រូវបានបកស្រាយជូនជនរងគ្រោះដោយអង្គការដែលបានជួយបំពេញពាក្យបណ្តឹងជូនពួកគាត់ឬក៏អត់។ វាក៏មិនត្រូវបានដឹងដែរពីកម្រិតនៃការបកស្រាយថាអ្វីនឹងកើតឡើងចំពោះឯកសារទាំងនេះនៅក្នុងនីតិវិធី ឬក្រោយមកទៀត។

45. ការលើកលែងមានកំណត់មួយ ចំពោះគោលជំហរនេះ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មក្នុងអំឡុងពេលជំនុំជម្រះ។ ដំណើរការនៃការជ្រើសរើសបុគ្គលទាំងនេះដើម្បីធ្វើសក្ខីកម្ម គឺជាប់ពាក់ព័ន្ធនឹងការពិភាក្សាលម្អិតរវាងដើមបណ្តឹងរដ្ឋប្បវេណីតាមសំណួរ និងមេធាវីរបស់ពួកគាត់ ហើយមានតែអ្នកដែលជូនដំណឹងពីការយល់ព្រមផ្តល់សក្ខីកម្មជាសាធារណៈតែប៉ុណ្ណោះដែលត្រូវបានដាក់បញ្ចូល។ សហមេធាវីនាំមុខមិនមានការជំទាស់ចំពោះការធ្វើចំណាត់ថ្នាក់ឡើងវិញ ដែលគ្របដណ្តប់ប្រធានបទដែលបានដោះស្រាយមាននៅក្នុងសក្ខីកម្មជាសាធារណៈរបស់ពួកគេនោះទេ (ទោះបីជាព័ត៌មានផ្សេងទៀតអំពីដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ រួមទាំងអាសយដ្ឋាន

ស្តីពីវិធានការការពារ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០។ ឯកសារ D421 [សម្ងាត់] ដីកាសម្រេចស្តីពីវិធានការការពារ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១០។ ឯកសារ D422 [សម្ងាត់] ដីកាសម្រេចស្តីពីវិធានការការពារ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០។

[73] សូមមើល ឯកសារ D389 ដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានវិធានការការពារ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១០។

ទំនាក់ទំនងលម្អិត និងលេខឯកសារអត្តសញ្ញាណ ក៏ដូចជាបញ្ហារសើបដែលមិនប៉ះពាល់ដោយការផ្តល់សក្ខីកម្មរបស់ពួកគាត់[74] គួរតែរក្សាការសម្ងាត់ក៏ដោយ)។ ទោះជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាការបញ្ជាក់បន្ថែមអំពីតម្រូវការដើម្បីការពារព័ត៌មានរសើបពីអ្នកដែលបានបដិសេធមិនចែករំលែករឿងរ៉ាវរបស់ពួកគេជាសាធារណៈ[75] ឬពីអ្នកដែលមិនទាន់ទទួលបានឱកាសដើម្បីបង្ហាញអំពីការយល់ឃើញរបស់ពួកគេលើសំណួរនេះតែប៉ុណ្ណោះ។

46. ភាគច្រើននៃសំភារៈ ដែលបានកំណត់ខាងលើ មានបញ្ហាត្រង់ចំណុចមិនច្បាស់លាស់ចំនួនពីរដែលបានកំណត់នៅក្នុងកថាខណ្ឌ ៣១ ខាងលើ។ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលមាននៅក្នុងភស្តុតាងក្នុងសំណុំរឿង - ដែលត្រូវបានសន្មតថាត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាសាធារណៈ - រួមមានព័ត៌មានដែលមានលក្ខណៈរសើប ឬ ឯកជន ប៉ុន្តែវាហាក់ដូចជាមិនស្ថិតនៅក្នុងប្រភេទនៃសំភារៈសម្ងាត់មួយយោងតាមមាត្រា ៥ មាត្រា ៦ ឬ មាត្រា ៧ នៃសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ។ ហើយភាគច្រើននៃឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ក្នុងសំណុំរឿងមិនស្ថិតក្នុងប្រភេទជាក់លាក់ណាមួយ ជាសំភារៈសាធារណៈ ឬ សម្ងាត់ ពោលគឺ វាមិនត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ ឬ សម្ងាត់ អនុលោមតាមសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ។

### *៤.៣ ការធ្វើចំណាត់ថ្នាក់បច្ចុប្បន្ននៃសំភារៈដើមបណ្តឹងរដ្ឋប្បវេណី*

47. ការធ្វើចំណាត់ថ្នាក់បច្ចុប្បន្ននៃឯកសារទាំងនេះមានលក្ខណៈខុសគ្នាច្រើនប្រភេទ។

48. ឯកសារទាំងអស់ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងជាឯកសារសម្ងាត់។ ទោះយ៉ាងណាក៏ដោយ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងទម្រង់បែបបទអំពីព័ត៌មានបន្ថែមជាច្រើនពាន់ច្បាប់នៅក្នុងភស្តុតាង (ឯកសារE3) ឥឡូវនេះបង្ហាញនៅក្នុងសំណុំរឿងជាមួយនឹងការចាត់ថ្នាក់របស់ពួកគេ

---

[74] សូមមើលឧទាហរណ៍ខាងក្រោមនៅកថាខណ្ឌ ៤៨ (ii)

[75] សូមមើលឧទាហរណ៍ ឯកសារលេខ **E307/6** សំណើរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧ (៤) ដែលស្នើសុំទទួលយកជាភស្តុតាងនូវសក្ខីកម្មផ្ទាល់មាត់ និងឯកសារ ព្រមទាំងភស្តុតាង ដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ កថាខណ្ឌ២២។

ដែលត្រូវបានសម្គាល់ថាជាសាធារណៈ និងដោយគ្មានការកោលសលុបឡើយ[76]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនអាចបង្ហាញអំពីការសម្រេចចិត្តផ្លូវការណាមួយចំពោះការធ្វើចំណាត់ថ្នាក់ឡើងវិញនេះទេ។ វាហាក់បង្ហាញថាឯកសារភាគច្រើន ឬទាំងអស់ ត្រូវបានយោងទៅសវនាការជាសាធារណៈ ឬពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មជាសាធារណៈ។ ទោះយ៉ាងណាក៏ដោយ ឯកសារជាច្រើនផ្សេងទៀតដែលត្រូវបានយោង ឬដកស្រង់នៅក្នុងសវនាការសាធារណៈ ឬដែលត្រូវបានដាក់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្ម ត្រូវបានទទួលយកជាភស្តុតាងដោយមិនត្រូវបានចាត់ថ្នាក់ជាសាធារណៈឡើងវិញអ្វីឡើយ ហើយបន្តនៅតែជាសម្ងាត់។ វាក៏មិនបង្ហាញដែរថា ការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នត្រូវបានធ្វើឡើងចំពោះឯកសារ ដើម្បីកំណត់អត្តសញ្ញាណវត្ថុតាងនៅក្នុងឯកសារទាំងនោះដែលមិនទាក់ទងទៅនឹងសក្ខីកម្មដែលបានផ្តល់ក្នុងសវនាការសាធារណៈ ហើយដែលអាចបង្កព្យសនកម្មដល់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកផ្សេងទៀតប្រសិនបើវាត្រូវបានលាតត្រដាង។ ដោយសារធនធានមានដែនកំណត់ សហមេធាវីនាំមុខមិនអាចពិនិត្យឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមើលទៅបានធ្វើចំណាត់ថ្នាក់សាធារណៈទាំងអស់ជាប្រព័ន្ធទេ ប៉ុន្តែពិនិត្យដោយផ្នែក ឃើញថាយ៉ាងហោចណាស់ឯកសារខ្លះក្នុងចំណោមឯកសារទាំងនេះ (ឥឡូវត្រូវបានចាត់ថ្នាក់ជាសាធារណៈដោយមិនបានកោសលុប) រួមបញ្ចូលព័ត៌មានរសើបខ្លាំងណាស ដែលវាហាក់ដូចជាមិនត្រូវបង្ហាញជាសាធារណៈទេ។ឧទាហរណ៍៖

(i) នៅក្នុងទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ (VIF) មួយ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាអំពី "ការថប់បារម្ភយ៉ាងខ្លាំង ការបាក់ទឹកចិត្ត និងការសុបិន្តអាក្រក់" របស់គាត់ដែលគាត់កំពុងទទួលការព្យាបាលដោយពេទ្យជំនាញផ្នែកផ្លូវចិត្ត និង "បានលេបថ្នាំយ៉ាងច្រើន"។ ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ (VIF) មានលិខិតរបស់ពេទ្យជំនាញផ្នែកផ្លូវចិត្តដែលបានរៀបរាប់យ៉ាងលម្អិតអំពីជំងឺបាក់ស្បាត (PTSD) របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបណ្តាលឱ្យ "មានការបំផ្លាញយ៉ាងធ្ងន់ធ្ងរទៅលើមុខងារដំណើរការ"របស់គាត់ក៏ដូចជាកំណត់ត្រាជំងឺផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជិត៥០ ទំព័រ នៃ ។ ទម្រង់

[76] ស្វែងរកក្នុង Zylab សំណុំរឿង ០០២ មូលដ្ឋានទិន្នន័យឯកសារសម្រាប់ការចាត់ចំណាត់ថ្នាក់ = សាធារណៈ និងប្រភេទកំណត់ត្រា = ទម្រង់ពាក្យសុំរបស់ជនរងគ្រោះ មានលទ្ធផលចំនួន៤៥១។ វាទំនងថាតួលេខត្រឹមត្រូវ គឺខ្ពស់ជាងនេះ ពីព្រោះ metadata សម្រាប់ប្រភេទកំណត់ត្រា មិនត្រូវបានដាក់បញ្ចូលជាទៀងទាត់សម្រាប់ឯកសារទាំងអស់ទេ ហើយទម្រង់ព័ត៌មានបន្ថែមភាគច្រើន ត្រូវបានចាត់ជាប្រភេទកំណត់ត្រាផ្សេងទៀត។ ការស្វែងរកក្នុង Zylab សម្រាប់ការចាត់ចំណាត់ថ្នាក់ = សាធារណៈ និងចំណងជើង = *ព័ត៌មានបន្ថែម* មានលទ្ធផលចំនួន១០៨ ប៉ុន្តែលុបចេញនូវឯកសារដែលមានចំណងជើងជាភាសាបារាំង។

បែបបទស្ដីពីព័ត៌មានជនរងគ្រោះនេះត្រូវបានយោងនៅក្នុងសវនាការរបស់តុលាការ និង ក្នុងវគ្គនៃសេចក្ដីថ្លែងការណ៍ ប៉ុន្តែមិនទាក់ទងនឹងស្ថានភាពផ្លូវចិត្ត ឬការព្យាបាលរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ[77] ។

(ii) ទម្រង់បែបបទស្ដីពីព័ត៌មានជនរងគ្រោះ របស់ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ពិពណ៌នាអំពីរបៀបដែលកម្មាភិបាល "បានប្រើមែកឈើដើម្បីរុកចូលក្នុង ប្រដាប់ភេទរបស់ [...] បណ្ដាលឱ្យហូរឈាម"។ ខណៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានផ្ដល់ភស្ដុតាងនៅក្នុងសវនាការ សំណួរដែលពាក់ព័ន្ធនឹងឧបទ្ទវហេតុនៃអំពើហិង្សាផ្លូវភេទមិនត្រូវបានលើកឡើងនៅក្នុងសវនាការនោះទេ។ ក្នុងករណីណាក៏ដោយ យោងតាមនីតិវិធីរបស់អង្គជំនុំជម្រះ សក្ខីកម្មណាមួយដែលបានផ្ដល់ជាសាធារណៈអំពីឧបទ្ទវហេតុបែបនេះ នឹងមិនត្រូវបានអនុញ្ញាតឱ្យបង្ហាញឈ្មោះជនរងគ្រោះជាសាធារណៈទេ (សូមមើលកថាខ័ណ្ឌ ៥៩ (ខ) ខាងក្រោម)។[78]

49. ការប៉ុនប៉ងរបស់សហមេធាវីនាំមុខក្នុងការស្វែងយល់ពីដំណើរការ ឬមូលដ្ឋានដែលឯកសារទាំងនេះ ត្រូវបានផ្ដល់ចំណាត់ថ្នាក់ជាសាធារណៈដោយមិនបានកោសលុប បានបង្ហាញថាមិនបានជោគជ័យនោះទេ។ ការពិភាក្សាក្រៅផ្លូវការមួយចំនួនជាមួយបុគ្គលដែលទទួលបន្ទុកនៅពេលធ្វើការជំនុំជម្រះ ស្នើថា វាអាចកើតឡើងដោយអចេតនា។ ដូចដែលបានរៀបរាប់ខាងក្រោម វាចាំបាច់ណាស់ដែលស្ថានភាពនេះត្រូវបានកែតម្រូវ។

50. ដូចបានរៀបរាប់ខាងលើក្នុងកថាខណ្ឌទី១០ ឯកសារសម្ងាត់មួយចំនួននៅក្នុងភស្ដុតាងក្រោយមកត្រូវបានស្នើឡើងសម្រាប់អង្គជំនុំជម្រះសាលាដំបូង ធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ ក្រោយពីបានសំអាងនៅក្នុងសាលក្រមសំណុំរឿង ០០២/០២ រួមទាំងឯកសារដើមបណ្ដឹងរដ្ឋប្បវេណីមួយ ចំនួនផងដែរ[79]។ អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់លម្អិតថាតើឯកសារទាំងនេះត្រូវបានកំណត់យ៉ាងដូចម្ដេច ហើយឯកសារដើមបណ្ដឹងរដ្ឋប្បវេណីសម្ងាត់មួយចំនួនដែលបាន

[77] ឧបសម្ព័ន្ធ ក ផ្នែក ៥៦។

[78] ឧបសម្ព័ន្ធ ក ផ្នែក ៤៧។

[79] ឯកសារលេខ **E467/6.5** (សម្ងាត់) ឧបសម្ព័ន្ធ៥៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងសេចក្ដីថ្លែងការណ៍បន្ថែមដែលតម្រូវឱ្យ ពិនិត្យមើលឡើងវិញសម្រាប់ការកោសលុបមុនពេលធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩។

យោងនៅក្នុងសាលក្រម ទំនងមិនត្រូវបានស្នើសុំឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញនោះទេ[80]។ នៅទីបំផុត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងទម្រង់បែបបទអំពីព័ត៌មានបន្ថែម ដោយទុកបញ្ហានេះ ឱ្យអង្គជំនុំជម្រះជាអ្នកសម្រេចដោះស្រាយ[81]។

51. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង*ពិតជា*បានចាត់ថ្នាក់ឡើងវិញជាសាធារណៈចំពោះឯកសារមួយចំនួនធំផ្សេងទៀត ដែលរួមមាន កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រវត្តិរូប និងចម្លើយសារភាព[82]។ សហមេធាវីនាំមុខមិនទាន់មានលទ្ធភាពពិនិត្យឯកសារទាំងនេះ ដើម្បីកំណត់ថា តើមានឯកសារណាមួយពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ។

52. ឯកសារភាគច្រើនដែលនៅសេសសល់ក្នុងសំណុំរឿង ដែលពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណីនៅតែជាឯកសារសម្ងាត់ក្នុងសំណុំរឿង ០០២ ហើយមិនទាន់ត្រូវបានពិចារណាធ្វើចំណាត់ថ្នាក់ឡើងវិញនៅឡើយនោះទេ។

53. ដូចបានកត់សម្គាល់ក្នុងផ្នែក ២.២ ខាងលើ ឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈរួចហើយក្នុងសំណុំរឿងផ្សេងទៀត (ដោយមាន ឬមិនមានធ្វើការកោសលុប)។

## ៥. សំណើទាក់ទងនឹងការធ្វើចំណាត់ប្រភេទឡើងវិញឱ្យបានសមស្របចំពោះឯកសារដើម បណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងសំណុំរឿង

### *៥.១ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងភស្តុតាង*

---

[80] សូមមើលឧទាហរណ៍ សាលក្រមអង្គជំនុំជម្រះសាលាដំបូង **E465** ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ជើងទំព័រ១០៨៣ យោងទៅឯកសារលេខ**E3/4828**, ជើងទំព័រ៨៩២០ និង ៨៩២១ យោងទៅឯកសារលេខ **E3/5863**;ជើងទំព័រ ១០៤៧៦ និង ១០៤៨៤ យោងទៅឯកសារលេខ **E3/6260**;ជើងទំព័រ ១០៤៨៤ យោងទៅឯកសារលេខ **E3/6314**; ជើងទំព័រ១០៨៩៦ យោងទៅឯកសារលេខ **E3/4800**។

[81] ឯកសារលេខ **E467/6** ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងមកជាឯកសារសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ១១ និង១៨។

[82] ឯកសារលេខ **E467/6** ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងមកជាឯកសារសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ និងឯកសារលេខ **E467/6.1** ឧបសម្ព័ន្ធ ១៖ ភស្តុតាងដែលបានដាក់ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២។

54. ដូចដែលបានកំណត់ខាងលើ តាមការប៉ាន់ស្មាន មានឯកសារជាង ៤០០០ ដែលមានប្រភពចេញមកពី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ចូលទៅក្នុងភស្តុតាង និងត្រូវបានផ្តល់លេខសម្គាល់ E3 ក្នុងសំណុំរឿង ០០២។

55. ទោះបីជាមានការសម្រេចខុសគ្នារហូតមកដល់បច្ចុប្បន្នក៏ដោយ សហមេធាវីនាំមុខសន្និដ្ឋានថា រាល់ឯកសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងភស្តុតាង គួរតែត្រូវបានសម្រេចឱ្យបានដូចៗគ្នា។ យោងតាមមាត្រា ៤(ឃ) នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ ឯកសារទាំងនេះត្រូវបានសន្មតថាត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយ យោងតាមមាត្រា ៩.២ សំណៅសាធារណៈនៃឯកសារទាំងនេះអាចធ្វើឡើងបាន ដោយធ្វើការកោសលុបព័ត៌មានសម្ងាត់ទាំងអស់ចេញពីក្នុងឯកសារ។ ករណីនេះចោទជាបញ្ហាថាតើឯកសារណាខ្លះក្នុងឯកសារទាំងនេះត្រូវចាត់ទុកជាឯកសារសម្ងាត់។

56. ដូចដែលបានកំណត់ខាងលើ មាត្រា ៧.៤ នៃសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញតម្រូវឱ្យកោសលុបអាសយដ្ឋានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះ ពីទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ដែលត្រូវបានចាត់ថ្នាក់ឡើងវិញជាឯកសារសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទព័ត៌មានផ្សេងទៀត មិនត្រូវបានកំណត់ច្បាស់លាស់នៅក្នុងសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញថាជាឯកសារសម្ងាត់ ឬតម្រូវឱ្យធ្វើការកោសលុបនោះទេ ទោះបីជាវាហាក់ដូចជាហេតុផលល្អគួរធ្វើដូច្នេះក៏ដោយ។

*៥.១.២ ហេតុផលនៃការកោសលុបសំភារៈភស្តុតាងមុនពេលការធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ*

57. ប្រភេទមួយចំនួននៃព័ត៌មានឯកជន និងព័ត៌មានរសើប ដែលត្រូវបានកំណត់ខាងលើក្នុងផ្នែក ៤.២ មិនស្ថិតក្នុងចំណោមប្រភេទព័ត៌មានសម្ងាត់ ដែលមានរៀបរាប់នៅក្នុងសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ ត្រង់មាត្រា ៤ មាត្រា ៥ មាត្រា ៦ ឬ មាត្រា ៧ នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ មានហេតុផលល្អមួយចំនួន ដូចបានរៀបរាប់លម្អិតខាងក្រោម ដើម្បីឱ្យអង្គជំនុំជម្រះចាត់ទុកព័ត៌មាននេះជាព័ត៌មានសម្ងាត់។

*ភាពស៊ីសង្វាក់គ្នានៃវិធីសាស្ត្រទាក់ទងនឹងឯកជនភាព*

58. នៅក្នុងសេចក្តីសម្រេចមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សំភារៈគួរតែត្រូវបានដកចេញពីក្របខ័ណ្ឌសាធារណៈ ក្នុងករណីផលប្រយោជន៍នៃតម្លាភាពនៅមានទម្ងន់ទាបជាងឯក

ជនភាពនៃបុគ្គលពាក់ព័ន្ធ។ ដូចគ្នានេះដែរ អត្ថបទច្បាប់របស់តុលាការ ការពារប្រភេទព័ត៌មានមួយចំនួន ដែលជាក់ស្ដែងផ្អែកលើការព្រួយបារម្ភអំពីឯកជនភាពនេះឯង។

59. ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឧទាហរណ៍មួយចំនួន៖

(ក) ការទទួលស្គាល់នៅក្នុងសេចក្ដីណែនាំអនុវត្តស្ដីពីការធ្វើចំណាត់ថ្នាក់ថា ព័ត៌មានអំពីសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទ គឺព័ត៌មានសម្ងាត់បំផុត[83] ហើយអាសយដ្ឋានទំនាក់ទំនងលម្អិតរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី គឺព័ត៌មានសម្ងាត់[84]។

(ខ) សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបញ្ជាក់ថា ភស្តុតាងពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តលើតតិយជន គួរត្រូវបានស្ដាប់នៅក្នុងសវនាការអសាធារណៈ (អនុលោមតាមមាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា) ដើម្បីជៀសវាងការបង្ហាញអត្តសញ្ញាណភាគីទីបីទាំងនោះ[85]។

(គ) ដីកាសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់កំណត់ព័ត៌មានលំអិតផ្ទាល់ខ្លួន ពាក់ព័ន្ធនឹងសាក្សី ដែលត្រូវបានកោសលុបចេញពីឯកសារ និងមិនត្រូវបានអាននៅក្នុងតុលាការ ដែលសាក្សីនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរ ហើយអាចប្រឈមនឹងការសងសឹក[86]។

---

[83] សេចក្ដីណែនាំអនុវត្តស្ដីអំពីចំណាត់ប្រភេទ មាត្រា៦ (គ)។

[84] សេចក្ដីណែនាំអនុវត្តស្ដីអំពីចំណាត់ប្រភេទ មាត្រា៥.១ (ង) និង៧.៤។

[85] ឯកសារលេខ **E1/255.1** [កែតម្រូវ៤] ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ទំព័រ៣ ជួរទី៨-១៨ បន្ទាប់ពី [09.10.10]។ សូមមើលផងដែរ ឯកសារលេខ **E1/272.1** [កែតម្រូវ១] ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ទំព័រ១១ ជួរទី១ –ទំព័រ១២ ជួរទី១១ និងទំព័រ៤៤ ជួរ៩-១៨។ លេខឯកសារ **E1/282.1** [កែតម្រូវ១] ប្រតិចារឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ទំព័រ២៨ ជួរ១១-១៣ និងទំព័រ១០៩ ជួរ៨-១៧។

[86] **សំណុំរឿង ០០១ – ឯកសារលេខ D288/6.135** សេចក្ដីសម្រេចលើសំណើសុំវិធានការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី E2/62 និង E2/89 និងសាក្សី KW-10 និង KW-24 ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ៧-៩។

(ឃ) វិធានការបង្ការដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីការពារអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្ម ដែលការលាតត្រដាងអាចបង្កហានិភ័យដល់សុខភាពផ្លូវអារម្មណ៍ និងផ្លូវចិត្ត[87]។

60. គោលការណ៍ទាំងនេះគួរតែត្រូវបានអនុវត្តឱ្យបានស៊ីសង្វាក់គ្នា។ ការការពារដែលផ្តល់ជូនដល់អ្នកដែលបានផ្តល់សក្ខីកម្ម ឬ ភាគីទីបី ដែលបានលើកឡើងនៅក្នុងសក្ខីកម្ម គួរផ្តល់ជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់ពួកគេ។ ការការពារឯកជនភាពដែលបានផ្តល់ជូនដល់ជនជាប់ចោទ (ដូចជាការការពារទាក់ទងនឹងព័ត៌មានសុខភាព) គួរផ្តល់ជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ចំពោះផ្នែកនៅក្នុងឯកសារដែលមានព័ត៌មានឯកជនទាក់ទងនឹងអាសយដ្ឋានទំនាក់ទំនងលម្អិតរបស់បុគ្គល ឯកសារអត្តសញ្ញាណ លក្ខខណ្ឌសុខភាពផ្លូវកាយ ឬផ្លូវចិត្ត ឬការព្យាបាល បទពិសោធន៍នៃអំពើហឹង្សាផ្លូវភេទចំពោះពួកគេ ឬបញ្ហាផ្ទាល់ខ្លួនផ្សេងទៀតទាក់ទងនឹងជីវិតអាពាហ៍ពិពាហ៍ និងជីវិតផ្លូវភេទរបស់ពួកគេ, ព័ត៌មានទាំងនេះគួរតែរក្សាការសម្ងាត់ដោយមិនគិតពីភាគីណាមួយ (ឬភាគីទី៣) ដែលរងផលប៉ះពាល់នោះឡើយ។ ដូចគ្នានេះដែរ ក៏មិនគួរបញ្ចេញព័ត៌មានណា ដែលអាចបង្កឱ្យមានការសងសឹក ឬ ប៉ះពាល់ដល់ផ្លូវអារម្មណ៍ ឬ ផ្លូវចិត្តនោះដែរ។

61. សហមេធាវីនាំមុខទទួលយកថា កាលៈទេសៈមួយចំនួន គឺតម្រូវឱ្យពត៍មានទាក់ទងនឹងប្រធានបទរសើបគួរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ជាពិសេស ត្រង់ផ្នែកដែលមានការជំទាស់តវ៉ានៅក្នុងកិច្ចដំណើរការនីតិវិធី និងត្រង់ផ្នែកណាដែលបានសម្រេចនៅក្នុងសាលក្រមតុលាការ។ ការវាយតម្លៃតាមករណីជាក់ស្តែងនីមួយៗត្រូវធ្វើឡើងដើម្បីវាយតម្លៃលើបញ្ហាទាំងនេះ។

*ការកោសលុបចាំបាច់ត្រូវធ្វើឡើងដើម្បីបញ្ចៀសកុំឱ្យប៉ះពាល់ទៅដល់វត្ថុបំណងនៃវិធានការផ្សេងៗទៀត*

62. ជាងនេះទៀត ប្រភេទនៃការកោសលុបខ្លះគឺជាការចាំបាច់ ពីព្រោះប្រសិនបើពុំមានការកោសលុបទាំងនោះទេ ឯកសារដែលត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈនៅក្នុងសំណុំរឿងនឹងបង្ហាញអំពីព័ត៌មានដែលត្រូវចាត់ទុកជាឯកសារសម្ងាត់ នៅពេលព័ត៌មាននោះមាននៅក្នុងឯកសារដទៃទៀត។

63. ឧទាហរណ៍ មាត្រា៧.៤ នៃសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញតម្រូវថា ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់ម្ចាស់បណ្តឹង និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

---

[87] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៥។

ប្បវេណីត្រូវលុបចេញពីទម្រង់បែបបទព័ត៌មានជនរងគ្រោះនៅពេលត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ។ ប៉ុន្តែទោះជាយ៉ាងណាក្តី បទបញ្ញត្តិនេះហាក់ដូចជាមើលរំលងថាព័ត៌មានលម្អិតក៏អាចលេចឡើងផងដែរនៅក្នុងឯកសារដទៃទៀត ក្នុងនោះរួមមានទម្រង់បែបបទព័ត៌មានបន្ថែម កំណត់ហេតុស្តាប់ចម្លើយ និង ឯកសារសម្ភាសន៍របស់ DC-Cam។ វត្ថុបំណងយ៉ាងច្បាស់នៃមាត្រា៧.៤ គឺដើម្បីការពារព័ត៌មានឯកជនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពុំមានផលប្រយោជន៍សាធារណៈក្នុងការដាក់បង្ហាញព័ត៌មាននេះឡើយ។ វត្ថុបំណងនោះនឹងត្រូវធ្វើឱ្យអន្តរាយប្រសិនបើព័ត៌មានដដែលនេះត្រូវបានបង្ហាញ តាមរយៈឯកសារដទៃទៀត(មិនកោសលុប) នៅក្នុងកំណត់ត្រាសាធារណៈនៃសំណុំរឿង។

64. ស្រដៀងគ្នានេះ ខណៈដែលអង្គជំនុំជម្រះសាលាដំបូងបានការពារយ៉ាងជាក់ច្បាស់នូវព័ត៌មានមួយចំនួនមិនឱ្យមានការបង្ហាញនៅក្នុងសវនាការ ការកោសលុបនឹងមានលក្ខណៈចាំបាច់ដើម្បីធានាថាព័ត៌មានដែលត្រូវបានការពារមិនត្រូវបានបង្ហាញតាមរយៈឯកសារដទៃទៀតឡើយ។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានតម្រូវថា ត្រូវចាត់វិធានការការពារអត្តសញ្ញាណរបស់ជនរងគ្រោះផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់[88]។ ក៏ប៉ុន្តែ បុគ្គលដដែលត្រូវបានសរសេរឈ្មោះក្នុងឯកសារនៅលើសំណុំរឿង[89] ។

65. ឧទាហរណ៍ចំនួនពីរនេះដែលសហមេធាវីនាំមុខកំណត់បានយ៉ាងច្បាប់រួចជាស្រេចហើយ។ ការពិនិត្យហ្មត់ចត់នឹងមានលក្ខណៈចាំបាច់ ដើម្បីកំណត់នូវឧទាហរណ៍ជាក់ស្តែងផ្សេងទៀត ក្នុងករណីដែលបញ្ហានេះកើតឡើង។

### *៥.១.៣ មូលដ្ឋានគតិយុត្តសម្រាប់ការកោសលុប*

66. ទោះបីជាសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ បង្កើតនូវប្រភេទសម្ងាត់បំផុតសម្រាប់ឯកសារ និងព័ត៌មានដែលស្ថិតក្រោមវិធានការការពារយ៉ាងណាក៏ដោយ[90] ក៏វាហាក់ដូចជាពុំមានលទ្ធភាពក្នុងការគ្រាន់តែស្នើឡើងនូវវិធានការការពារនៅចុងបញ្ចប់នៃរឿងក្តី ដើម្បីការពារការបង្ហាញឯកសារនេះនៅពេលឯកសារត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញនោះឡើយ។ ជាធម្មតា

---

[88] ឯកសារលេខ **E1/272.1** [កែតម្រូវ១] ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ទំព័រ៩៤ ជួរទី១៣-១៨។ ឯកសារលេខ **E1/272.1** [កែតម្រូវ១] ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥។

[89] ឧបសម្ព័ន្ធ ក ផ្នែក ៤៨, ៤៩, ៥០, ៥១។

[90] មាត្រាទី៦(ខ) នៃសេចក្តីណែនាំអនុវត្ត។

វិធានការបែបនេះអាចត្រូវបានស្នើឡើងតែក្នុងរយៈពេល១៥ថ្ងៃ ក្រោយពេលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ[91] ដែលជាការបង្ហាញថាវិធានការទាំងនេះមានគោលបំណងបម្រើឱ្យកិច្ចនីតិវិធីជាជាងការកោសលុបលើសម្ភារៈនៅក្នុងកំណត់ត្រាសាធារណៈអចិន្ត្រៃយ៍នៃសំណុំរឿង។

67. ក៏ប៉ុន្តែ ថាតើវាស្ថិតនៅក្នុងទស្សនៈទានផ្លូវការនៃ "វិធានការការពារ"ឬយ៉ាងណានោះ សហមេធាវីនាំមុខសូមគោរពស្នើសុំអង្គជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះរក្សាឆន្ទានុសិទ្ធិក្នុងការអនុវត្តការធ្វើចំណាត់ថ្នាក់ឯកសារឬព័ត៌មានខុសពីអ្វីដែលបានបង្កើតដោយការសន្មត ដោយសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ។ ប្រការនេះត្រូវបានគាំទ្រដោយការប្រើពាក្យ "ស្ថិតក្រោមការធ្វើចំណាត់ប្រភេទផ្សេងអនុលោមតាមសេចក្តីសម្រេចរបស់តុលាការ" ដែលមានចែងនៅក្នុងមាត្រា៤ មាត្រា៥ និងមាត្រា៦ នៃសេចក្តីណែនាំអនុវត្ត។ វាជាការស្របគ្នាផងដែរទៅនឹងវិធាន២១ នៃវិធានផ្ទៃក្នុង ដែលតម្រូវថា អត្ថបទច្បាប់របស់ អ.វ.ត.ក គួរតែត្រូវបកស្រាយ "ក្នុងន័យការពារដល់ប្រយោជន៍របស់...ជនរងគ្រោះ" និង ថា សិទ្ធិរបស់ជនរងគ្រោះត្រូវបានគោរព នៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងមូល[92]។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះបានសម្រេចថាខ្លួនមានអំណាចទូលំទូលាយនៅក្នុងដំណើរការធ្វើចំណាត់ថ្នាក់ឡើងវិញ ដែលលើសពីអ្វីដែលបានរាប់បញ្ចូលយ៉ាងច្បាស់លាស់នៅក្នុងសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ[93]។

68. ប្រសិនបើមានចំណុចណាមួយនៅមានមន្ទិលសង្ស័យ អាចយោងដល់បទដ្ឋានអន្តរជាតិ[94]។ បទដ្ឋានទាំងនេះរួមមានតម្រូវការការពារដោយយន្តការយុត្តិធម៌ចំពោះឯកជនភាព ភាពថ្លៃថ្នូរ និង សុខមាលភាពចិត្តសាស្ត្ររបស់ជនរងគ្រោះ និងក្រុមគ្រួសារ[95]។ ប្រភេទព័ត៌មានជាក់លាក់ដែលត្រូវការ

[91] វិធាន២៩ (៣) នៃវិធានផ្ទៃក្នុង។

[92] វិធាន២១ (១) នៃវិធានផ្ទៃក្នុង និងវិធាន២១ (១) (ក)។

[93] សំណុំរឿង ០០១ - **F31/1** [ជាសាធារណៈកោសលុប] សេចក្តីសម្រេចស្តីពីការចាត់ចំណាត់ថ្នាក់ឡើងវិញនៃវីដេអូ លេខ **E3/247R** និងលើការប្រែប្រួលនៃវិធានការការពារដែលពាក់ព័ន្ធ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ ទំព័រ៤។

[94] កិច្ចព្រមព្រៀងរបស់ អ.វ.ត.ក មាត្រា១២។ ច្បាប់ អ.វ.ត.ក មាត្រា៣៣ថ្មី។

[95] សូមមើល ឧទាហរណ៍៖ គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ សេចក្តីសម្រេចមហាសន្និបាតរបស់អង្គការសហប្រជាជាតិ លេខ ៦០/១៤៧ ចុះថ្ងៃទី ២១ ខែមិនា ឆ្នាំ ២០០៦ មាត្រា ១០។ សេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភបំពាន សេចក្តីសម្រេចមហាសន្និបាតរបស់អង្គការសហប្រជាជាតិ លេខ ៤០/៣៤ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ មាត្រា ៦ (ឃ)។ សេចក្តីណែនាំលេខ 2012/29/EU របស់សភាអឺរ៉ុប និងក្រុមប្រឹក្សា ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បង្ហាញពីបទដ្ឋានអប្បបរមាស្តីអំពី

ការពាររួមមានសម្ភារៈពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ[96] និងព័ត៌មានអំពីស្ថានភាពសុខភាពផ្លូវចិត្ត និងផ្លូវកាយ[97]។ កាលបើលាតត្រដាងទៅអាចបង្កឱ្យមានការមើលងាយ ឬព្យសនកម្មទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះ តុលាការត្រូវបានតម្រូវឱ្យដាក់ចេញនូវការធានាប្រកបដោយប្រសិទ្ធភាពគ្រប់គ្រាន់ដើម្បីធានាថាខ្លួនមិនផ្សព្វផ្សាយនូវព័ត៌មានផ្ទាល់ខ្លួន (រួមទាំងដោយផ្តល់ជូនបុគ្គលដែលរងផលប៉ះពាល់នូវឱកាសក្នុងការស្នើសុំមិនបញ្ចេញព័ត៌មានទាំងនោះ)[98]។

### *៥.១.៤ វិធីសាស្ត្រដែលបានស្នើឡើងសម្រាប់ឯកសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងភស្តុតាង*

---

សិទ្ធិ ការគាំទ្រ និងការការពារជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការជំនួសសេចក្តីសម្រេចស្តីពីក្របខ័ណ្ឌការងាររបស់ក្រុមប្រឹក្សា មាត្រា២១-២២។ ពាក់ព័ន្ធកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ សូមមើលផងដែរ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៦៨(១) និង៦៨(២)។ *រឿងក្តី* រដ្ឋអាជ្ញា *តទល់នឹង* Tadic សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាដែលសុំវិធានការការពារសម្រាប់ជនរងគ្រោះ និងសាក្សី ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៥ កថាខណ្ឌ៣១-៤២។ ព្រឹត្តិប័ត្រអគ្គលេខាធិការ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ ស្តីពីភាពរសើបនៃព័ត៌មាន ការចាត់ចំណាត់ថ្នាក់ឯកសារ ការដាក់ឯកសារ និងការចូលមើលឯកសារ ST/SGB/2012/3 ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ផ្នែក៤.១ (ដាក់បញ្ចូលនូវព្រឹត្តិប័ត្រអគ្គលេខាធិការ ស្តីពីភាពរសើបនៃព័ត៌មាន ការចាត់ចំណាត់ថ្នាក់ឯកសារ និងការដាក់ឯកសារ ST/SGB/2007/6 ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ១.២)។

[96] សូមមើលឧទាហរណ៍៖ *រឿងក្តី* រដ្ឋអាជ្ញា *តទល់នឹង* Tadic សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាដែលសុំវិធានការការពារសម្រាប់ជនរងគ្រោះ និងសាក្សី ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៥ កថាខណ្ឌ៤៥-៥២។ ការរំលោភផ្លូវភេទជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ជាប្រព័ន្ធ និងជាទូទៅ ជាឧក្រិដ្ឋកម្ម និងការបង្ហាញពីអំពើហិង្សាខាងផ្លូវភេទទៅលើស្ត្រី និងកុមារី និងការទប់ស្កាត់៖ របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីអំពើហិង្សាលើស្ត្រី មូលហេតុ និងផលវិបាករបស់វា Dubravka Šimonović, A/HRC/47/26, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០១ កថាខណ្ឌ ១០០ (គ)។ ក្របខ័ណ្ឌច្បាប់ស្តីពីការរំលោភផ្លូវភេទ (model rape law) ៖ របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីអំពើហិង្សាលើស្ត្រី មូលហេតុ និងផលវិបាករបស់វា A/HRC/47/26/Add.1, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៣០ (គ)។ ការិយាល័យរដ្ឋអាជ្ញាតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារគោលនយោបាយស្តីពីឧក្រិដ្ឋកម្មផ្លូវភេទ និងយេនឌ័រ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ៨៨-៨៩។ អង្គការសហប្រជាជាតិ របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ អនុលោមតាមកថាខណ្ឌ២ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ៨០៨ (១៩៩៣) S/25704 ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៩៣ កថាខណ្ឌ១០៨។

[97] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស *រឿងក្តី Z តទល់នឹងប្រទេសហ្វាំងឡង់* លេខ 22009/93 សាលក្រម ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៧ ជាពិសេសនៅកថាខណ្ឌ ៩៥ និង១១៣។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស *រឿងក្តី Frâncu តទល់នឹងប្រទេសរ៉ូម៉ានី Romania* លេខ 69356/13 សាលក្រម ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ កថាខណ្ឌ៥១-៥៦ និង៦៥-៧៤។

[98] តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស *រឿងក្តី Vicent del Campo តទល់នឹងប្រទេសអេស្ប៉ាញ* លេខ 255527/13 សាលក្រម ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ៤៨-៥០, ៥៣។

69. ហេតុដូច្នេះ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំថា ឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ E3 គួរតែត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញយោងតាមគោលការណ៍ដូចខាងក្រោម៖

(i) ជាភស្តុតាង អ្វីទាំងអស់ត្រូវបានសន្មតថាជាឯកសារជាសាធារណៈ ប៉ុន្តែស្ថិតក្រោមការកោសលុប តាមការចាំបាច់

(ii) កម្មវត្ថុដែលស្ថិតនៅក្រោមប្រធានបទទាំងអស់ ដែលបានកំណត់នៅក្នុងផ្នែកទី៤.២ ខាងលើ គួរសន្មតចាត់ទុកថាតម្រូវឱ្យមានការកោសលុប

(iii) ប៉ុន្តែ នៅក្នុងករណីនីមួយៗ បញ្ហាទាំងនេះអាចទុកចំហរមិនកោសលុប៖ ឧទាហរណ៍ នៅក្នុងករណីដែលសម្ភារៈត្រូវធ្វើឱ្យទៅជាឯកសារសាធារណៈ តាមរយៈសក្ខីកម្មនៅក្នុងពេលជំនុំជម្រះក្តី ឬនៅក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីយល់ព្រមដោយបានយល់ដឹង។

### *៥.២ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមាននៅក្នុងភស្តុតាង*

70. ដូចដែលបានពន្យល់នៅក្នុងកថាខ័ណ្ឌ៣៦ ភាគច្រើននៃឯកសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងមិនត្រូវបានដាក់ចូលជាភស្តុតាង។ សហមេធាវីនាំមុខ ជឿថា ទម្រង់ព័ត៌មានជនរងគ្រោះ និង ទម្រង់ព័ត៌មានបន្ថែមចំនួនប្រហែល ១៤៤00 ស្ថិតក្នុងប្រភេទនេះ។ កំណត់ហេតុស្តាប់ចម្លើយ និង ឯកសារសម្ភាសន៍របស់ DC-Cam ជាច្រើន (រួមទាំងមួយចំនួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីផង)ក៏មិនមាននៅក្នុងភស្តុតាងដែរ។

71. ជាងនេះទៀត ភាគច្រើនលើសលុបនៃឯកសាររដ្ឋបាលពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី (ដូចជាលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ និង របាយការណ៍ផ្នែកគាំពារសាក្សី)មិនស្ថិតក្នុងភស្តុតាងទេ។

72. សហមេធាវីនាំមុខពិចារណាឃើញថា គោលការណ៍ដែលអនុវត្តចំពោះឯកសារទាំងនេះ ដែលមិនមែន E3 គឺមានលក្ខណៈខុសគ្នាទៅនឹងអ្វីដែលបានចែងខាងលើ។ ដោយហេតុថា ឯកសារមិនស្ថិតនៅក្នុងភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ផលប្រយោជន៍សាធារណៈក្នុងការចូលមើលឯកសារទាំងនេះអាចត្រូវបានចាត់ទុកថាមានចំនួនតិច។ ការណ៍នេះបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ ដែលមិនបានបង្កើតនូវសច្ចធារណ៍នៃប្រភេទសាធារណៈសម្រាប់ឯកសារទាំងនេះទេ។

73. ទោះបីជាយ៉ាងដូច្នេះក្តី និងជាពិសេសពាក់ព័ន្ធនឹងឯកសារមិនមែនរដ្ឋបាល វានៅតែជាចំណាប់អារម្មណ៍ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលចង់ឱ្យការរៀបរាប់បទពិសោធន៍ដែលបានឆ្លងកាត់នៅក្នុងឯកសារទាំងនេះ ត្រូវបានបង្ហាញឱ្យគេបានដឹង។ វាក៏អាចមានចំណាប់អារម្មណ៍ពីសាធារណជនផងដែរ ដែលចង់ឱ្យឯកសារទាំងនេះរួមចំណែកបម្រើឱ្យគោលបំណងអប់រំ និងកេរតំណែលរបស់ អ.វ.ត.ក។ ប៉ុន្តែទោះជាយ៉ាងណាក្តី សហមេធាវីនាំមុខសូមគោរពស្នើថា ឯកសារទាំងនេះមិនចាំបាច់សន្មតធ្វើឱ្យទៅជាឯកសារសាធារណៈឡើយ។ ផ្ទុយទៅវិញឯកសារទាំងនេះគួរតែធ្វើឱ្យទៅជាឯកសារសាធារណៈ ដោយផ្អែកលើគោលការណ៍យល់ព្រមជាបុគ្គល ក្នុងករណីដែលការយល់ព្រមនោះត្រូវបានជូនដំណឹងពេញលេញ។

74. តាមរយៈការពិនិត្យសំណុំរឿងសាធារណៈនៃសំណុំរឿង០០១ វាហាក់ដូចជាបង្ហាញថា នៅក្នុងសំណុំរឿងនោះ ភាគច្រើនបំផុតនៃឯកសារដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនោះរួមមាន បែបបទព័ត៌មានជនរងគ្រោះ និងឯកសាររដ្ឋបាលត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅជាឯកសារសាធារណៈ ដោយមិនគិតថាឯកសារទាំងនោះស្ថិតក្នុងភស្តុតាងឬយ៉ាងណានោះទេ[99]។ ក្នុងករណីស្ទើរតែទាំងអស់(ទោះបីជាមិនទាំងអស់ក្តី) ការកោសលុបមួយចំនួនត្រូវបានអនុវត្ត ប៉ុន្តែសម្រាប់តែពត៌មានផ្ទាល់ខ្លួនដូចជា អាស័យដ្ឋាន អាយុ អត្តសញ្ញាណលេខឯកសារ។ សហមេធាវីនាំមុខពិចារណាឃើញថាការធ្វើចំណាត់ថ្នាក់ឡើងវិញទាំងដុលអាចមិនសមស្របក្នុងសំណុំរឿង០០២[100]។ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះបានឆ្លងកាត់ឧក្រិដ្ឋកម្មជាច្រើន ដែលឧក្រិដ្ឋកម្មមួយចំនួនមានលក្ខណៈ បុគ្គលច្រើន។ បញ្ហាដែលបានលើកឡើងនៅក្នុងផ្នែកទី ៤.២ ខាងលើប៉ះពាល់ដល់ឯកសារមួយចំនួនធំ នៅក្នុងសំណុំរឿង។ ការធ្វើចំណាត់ថ្នាក់ឡើងវិញទាំងដុលទៅលើឯកសារទាំងនេះអាចខកខានមិនបានការពារឯកជនភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង មិនមានយុត្តិកម្មដោយកម្រិតប្រយោជន៍សាធារណៈដូចគ្នាទៅលើតម្លាភាពដែលឯកសារទាំងនោះមិនមែនជាផ្នែកមួយនៃភស្តុតាង ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

75. ហេតុដូចនេះ សហមេធាវីនាំមុខសូមគោរពស្នើសុំថា ឯកសារដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនស្ថិតក្នុងភស្តុតាងគួរតែនៅរក្សាសម្ងាត់ដដែល លើកលែងតែមានសំណើរជាបុគ្គលរបស់ដើមបណ្តឹងពាក់ព័ន្ធ

[99] ទោះជាយ៉ាងនេះក្តី សហមេធាវីនាំមុខ រកមិនឃើញឯកសារទាក់ទងនឹងសិទ្ធិវ័ន្តនៅក្នុងសំណុំរឿងផ្នែក ឯកសារសាធារណៈក្នុងសំណុំរឿង០០១ទេ។ នេះអាចបញ្ជាក់ថាឯកសារទាំងនេះសម្ងាត់ ប្រសិនបើឯកសារទាំងនោះស្ថិតនៅក្នុងសំណុំរឿង០០១។

[100] សហមេធាវីនាំមុខ កត់សម្គាល់ជាពិសេសថា ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ បានទទួលរងឧក្រិដ្ឋកម្មច្រើនជាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ រួមទាំងការរៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ។

ដែលស្នើសុំធ្វើចំណាត់ថ្នាក់ឡើងវិញ ដោយស្ថិតនៅក្រោមការកោសលុបតាមការស្នើសុំ។ ក៏ប៉ុន្តែ សហមេធាវីនាំមុខ សូមសង្កត់ថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទទួលនូវឱកាសពិតក្នុងការធ្វើសំណើ ដើម្បីអ្នកដែលចង់ឱ្យពត៌មានរបស់ខ្លួនមានលក្ខណៈសាធារណៈ គឺមិនត្រូវបានហាមឃាត់។

## ៦. សំណើពាក់ព័ន្ធនឹងនីតិវិធី និង ពេលវេលា

76. មានការពិចារណាគន្លឹះចំនួនបួន ដែលសំណើរបស់សហមេធាវីនាំមុខសូមរំលេច ពាក់ព័ន្ធនឹងដំណើរការសមស្របបំផុតសម្រាប់ធ្វើឱ្យវិវត្តទៅមុខលើការធ្វើចំណាត់ថ្នាក់ឡើងវិញ។

77. ទីមួយ វាជាការសំខាន់ដែលថា ដំណើរការធ្វើចំណាត់ថ្នាក់ឡើងវិញនេះកើតឡើងមុនពេលបណ្ណសាររបស់តុលាការត្រូវបានធ្វើឱ្យទៅជាឯកសារសាធារណៈក្នុងលក្ខណៈជាក់ស្តែង។ ដូចដែលបានកំណត់ខាងលើ ឯកសារជាច្រើនដែលមានព័ត៌មានបុគ្គលដែលមិនបានកោសលុបហាក់ដូចជាត្រូវបានផ្តល់នូវការធ្វើចំណាត់ថ្នាក់សាធារណៈដោយកំហុស។ កំហុសទាំងនេះត្រូវតែដោះស្រាយមុនពេលកំណត់ត្រានានាត្រូវបានបើកចំហរចំពោះសហគមន៍។ ផ្ទុយពីមុខគោលជំហដែលអង្គបុរេជំនុំជម្រះបានពិភាក្សា[101] ការពិតដែលថាឯកសារបានចាត់ចំណាត់ថ្នាក់ជាសាធារណៈមួយរយៈនេះ មិនមែនមានន័យថាការចាត់ចំណាត់ថ្នាក់នេះគួរតែត្រូវបានរក្សាទុកនោះទេ។ រហូតមកដល់ពេលនេះ សូម្បីតែឯកសារសំណុំរឿងដែលបានចាត់ចំណាត់ថ្នាក់ជា “សាធារណៈ” មិនទាន់មានសម្រាប់អ្នកនៅក្រៅតុលាការទេ។ មានឯកសារភាគច្រើនមិនអាចចូលមើលបានលើគេហទំព័ររបស់ អ.វ.ត .ក បានទេ។ ឯកសារខ្លះមាននៅលើបណ្តាញអ៊ីនធឺណិត ប៉ុន្តែ ពិបាកស្វែងរកបើគ្មានចំណេះដឹងជាដឹងមុនអំពីអត្ថិភាព និងខ្លឹមសាររបស់វា។ ដូច្នេះវាមិនទំនងទេដែលថាការការពារដែលទទួលបានដោយការចាត់ចំណាត់ថ្នាក់សម្ងាត់បានបាត់បង់តម្លៃរបស់វាចំពោះឯកសារទាំងនេះ។ អ្វីដែលសំខាន់គឺមិនមែនជាការចាត់ចំណាត់ថ្នាក់ដែលមានរហូតមកដល់បច្ចុប្បន្ននេះទេ ប៉ុន្តែត្រូវធានានូវការចាត់ចំណាត់ថ្នាក់សមស្របមុនពេលបង្កើតបណ្ណាសារសាធារណៈពិតប្រាកដមួយ ដែលអាចចូលមើលបាន។

78. ទីពីរ សហមេធាវីនាំមុខកត់សម្គាល់ថា ឯកសារជាច្រើនមាននៅក្នុងសំណុំរឿងលើសពីមួយករណី។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនក្នុងសំណុំរឿង០០២ ក៏កំពុងមានឋានៈក្នុងរឿងក្តីមួយឬរឿងក្តីផ្សេង

[101] សូមមើល ឧបសម្ព័ន្ធ ខ អ៊ីមែលពីមន្ត្រីក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះទៅកាន់សហមេធាវីនាំមុខអន្តរជាតិ ចុះថ្ងៃទី៥ ខែ វិច្ឆិកា ឆ្នាំ២០២១ និងកថាខណ្ឌ ១៧ ខាងលើ។

ទៀតផងដែរ។ ដើម្បីគ្រប់គ្រងហានិភ័យដែលថាការធ្វើចំណាត់ថ្នាក់មួយដែលផ្តល់ឱ្យក្នុងសំណុំរឿងមួយនឹងត្រូវកំណត់ដោយការធ្វើចំណាត់ថ្នាក់មិនមានសង្គតិភាពមួយនៅក្នុងរឿងក្តីមួយទៀតនោះ វិធីរួមក្នុងការធ្វើចំណាត់ថ្នាក់ឡើងវិញលើរឿងក្តីទាំងអស់របស់ អ.វ.ត.ក គឺជាការចាំបាច់។

79. ទីបី ភាគីត្រូវតែមានឱកាសបញ្ចេញមតិយោបល់ មុនពេលមានសេចក្តីសម្រេចលើការធ្វើចំណាត់ថ្នាក់ឡើងវិញ។ ការណ៍នេះឆ្លុះបញ្ចាំងពីគោលការណ៍យុត្តិធម៌ទូទៅ ជាពិសេសសិទ្ធិបញ្ចេញមតិយោបល់ ដែលតម្រូវថា ភាគីពាក់ព័ន្ធគួរតែមានសិទ្ធិបញ្ចេញមតិយោបល់ មុនពេលមានសេចក្តីសម្រេចមួយដែលប៉ះពាល់ដល់ពួកគេ។ លក្ខខណ្ឌតម្រូវដែលថាជនរងគ្រោះគួរមានសិទ្ធិបញ្ចេញមតិយោបល់លើបញ្ហាដែលប៉ះពាល់ដល់ផលប្រយោជន៍ពួកគេនៅក្នុងកិច្ចនីតិវិធីព្រហ្មទណ្ឌគឺត្រូវបានទទួលស្គាល់នៅក្នុងបទដ្ឋានអន្តរជាតិ[102] និងគឺជាមូលដ្ឋានសម្រាប់ការចូលរួមរបស់ជនរងគ្រោះឬដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះក្តីជាអន្តរជាតិ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីខ្លះ ការផ្សព្វផ្សាយនូវព័ត៌មានបុគ្គលដែលពួកគេបាន ចែករំលែកដល់តុលាការអាចមានប្រតិឃាតដល់ទំនាក់ទំនងគ្រួសារឬសហគមន៍។ ប៉ុន្តែការរិតត្បិតទាំងស្រុងលើសិទ្ធិចូលមើលព័ត៌មាននោះក៏អាចប៉ះពាល់ដល់លទ្ធផលដែលដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនចង់បានបំផុតពីតុលាការនេះ។ ជាការសំខាន់ដែលដើមបណ្តឹងរដ្ឋប្បវេណី អាចបញ្ចេញមតិយោបល់លើបញ្ហាទាំងនេះមុនពេលមានសេចក្តីសម្រេច។ ទស្សនៈ និងចំណង់ចំណូលចិត្តផ្ទាល់ខ្លួននឹងខុសគ្នា ដូច្នេះហើយដើមបណ្តឹងនីមួយៗត្រូវតែមានឱកាស តាមរយៈតំណាងតាមផ្លូវច្បាប់ ក្នុងការស្នើកោសលុប និងការផ្សព្វផ្សាយព័ត៌មានបុគ្គលរបស់ខ្លួន។ នៅក្នុងករណីណាក្តី ភាគីគឺជាបុគ្គលដែលស្ថិតក្នុងស្ថានភាពល្អបំផុត ក្នុងការកំណត់ថាតើព័ត៌មានណាក្នុងឯកសារសំណុំរឿងដែលអាចបង្កការព្រួយបារម្ភអំពីឯកជនភាព។ ប្រសិនបើគ្មានធាតុចូលពីបុគ្គលដែលរងការប៉ះពាល់ចំពោះបរិបទនេះទេ អង្គជំនុំជម្រះនឹងមិនអាចវាយតម្លៃលើបញ្ហានេះម្តងមួយៗបានឡើយ។

80. ទីបួន សហមេធាវីនាំមុខមានវេទយិទចំពោះធនធានមានកម្រិតរបស់តុលាការ និង ដឹងថាធនធានរបស់តុលាការបច្ចុប្បន្នកំពុងផ្តោតលើការចេញសាលដីកាស្តាពរនៃសំណុំរឿង០០២។ ដូច្នេះ ជាការសមហេតុផលសម្រាប់ភាគីក្នុងការប្រើប្រាស់ពេលវេលានេះធ្វើការពិនិត្យឡើងវិញទៅលើសម្ភារៈឯកសារសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញ ដើម្បីរៀបចំសារណាឱ្យបានរួចរាល់នៅចំពោះមុខអង្គជំនុំជម្រះ

---

102 សេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភបំពាន សេចក្តីសម្រេចមហាសន្និបាតអង្គសហប្រជាជាតិ ៤០/៣៤ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ១៩៨៥ កថាខណ្ឌ ៦ (ខ)។

មុនពេលចេញសាលក្រមស្ថាពរ។ នេះក៏ជាចំណុចមួយដែរ ពីព្រោះបច្ចុប្បន្ន ភាគី (ឬភាគីខ្លះ) បន្តរួម បញ្ចូល សមាជិកក្រុមខ្លះដែលមានភាពស៊ាំទៅនឹងរឿងក្តីនេះនិងសម្ភារៈក្នុងសំណុំរឿង។ បុគ្គលទាំង នោះស្ថិតក្នុងស្ថានភាពល្អបំផុតក្នុងការដាក់សារណា ប្រកបដោយប្រសិទ្ធផលលើបញ្ហានៃការធ្វើ ចំណាត់ថ្នាក់ឡើងវិញ និង អាចមិនស្ថិតក្នុងតំណែងបានយូរប៉ុន្មានទេ ផ្អែកលើសេចក្តីសម្រេចថ្មីៗ របស់ការិយាល័យរដ្ឋបាល។ ការពិភាក្សាជាមួយដៃគូខាងក្រៅក៏បានបង្ហាញផងដែរថា ការផ្តល់មូលនិធិ សម្រាប់ការចូលរួមពិគ្រោះជាមួយដើមបណ្តឹងរដ្ឋប្បវេណីដែលចាំបាច់ដើម្បីអនុវត្តការងារនេះអាច នឹងមានកាន់តែច្រើនប្រសិនបើការណែនាំអំពីនីតិវិធីត្រូវបានចេញដោយអង្គជំនុំជម្រះ។

81. ហេតុដូច្នេះ សហមេធាវីនាំមុខសូមគោរពស្នើថា អង្គជំនុំជម្រះផ្តល់សេចក្តីណែនាំភ្លាមៗសម្រាប់ ដំណើរការធ្វើចំណាត់ថ្នាក់ឡើងវិញ ដែលអាចអនុញ្ញាតឱ្យភាគីរៀបចំសារណាលើការធ្វើចំណាត់ ថ្នាក់ឡើងវិញ និង ការកោសលុបចាំបាច់មុនពេលចេញសាលដីកាស្ថាពរ។ សេចក្តីណែនាំក្នុងការបំភ្លឺ លើចំណុចមិនច្បាស់លាស់ដូចមានចែងខាងលើក្នុងកថាខណ្ឌ៣១ គឺជាការចាំបាច់ ដើម្បីអនុវត្តសេចក្តី ណែនាំលើមូលដ្ឋាននៃយោបល់ត្រឹមត្រូវនិងសំណើសមស្របដែលបានធ្វើឡើង។ ដោយគ្មានសេចក្តី ណែនាំឬការធ្វើចំណាត់ថ្នាក់ពីអង្គជំនុំជម្រះនោះ កិច្ចខិតខំប្រឹងប្រែងដែលត្រូវបានពង្រីកលើការស្វែង រកទស្សនៈពីដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗអាចជាការខាតបង់ ប្រសិនបើគោលការណ៍ដែលសន្មត ត្រូវអនុវត្តមិនត្រូវបានយល់ព្រមចុងក្រោយដោយអង្គជំនុំជម្រះ។ សហមេធាវីនាំមុខក៏កត់សម្គាល់ផង ដែរថា មានការរំពឹងទុកជាក់ស្តែងមួយដែលថា ការងារដែលចាំបាច់ត្រូវអនុវត្តលើបញ្ហានេះ នឹងមិនត្រូវ បានផ្តល់ថវិកាដោយការិយាល័យរដ្ឋបាល ឬម្ចាស់ជំនួយពីខាងក្រៅឡើយប្រសិនបើគ្មានសេចក្តី ណែនាំច្បាស់លាស់ពីអង្គជំនុំជម្រះ[103]។

82. សហមេធាវីនាំមុខដឹងថា ដំណើរការនេះអាចត្រូវបានមនុស្សមួយចំនួនយល់ថាជាការចំណាយមិន ចាំបាច់ និងនឹកស្មានមិនដល់ នៅពេលដែលការងាររបស់តុលាការត្រូវបានរំពឹងថា ឈានជិតដល់ ទីបញ្ចប់។ ប៉ុន្តែទោះបីជាការធ្វើចំណាត់ថ្នាក់ឡើងវិញអាចមិនសូវទាក់ទាញការចាប់អារម្មណ៍ និងមិន មានតម្រូវការ ដូចសវនាការជាសាធារណៈក៏ដោយ ក៏វាមិនមែនមិនសំខាន់សម្រាប់ការងារនិងកេរ

103 ដូចបានបញ្ជាក់ក្នុងសេចក្តីសម្រេចចុងក្រោយរបស់ការិយាល័យរដ្ឋបាលពាក់ព័ន្ធនឹងធនធានសម្រាប់សហមេធាវីនាំមុខអន្តរ ជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ សូមមើល ឯកសារ **F70** សំណើសុំដីកាបង្គាប់បន្ទាន់ដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋ ប្បវេណីក្នុងការធ្វើជាតំណាងដោយប្រសិទ្ធិភាព និងជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងឯកសារ **F70.1.7** ឧបសម្ព័ន្ធ ៨៖ អនុ ស្សារណៈសម្ងាត់ពីការិយាល័យរដ្ឋបាលទៅកាន់សហមេធាវីនាំមុខអន្តរជាតិ មូលហេតុសម្រាប់សេចក្តីសម្រេចលើសំណើសុំ ធនធានរបស់លោកស្រី ចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២១ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ កថាខណ្ឌ១៥។

ដំណែលតុលាការនោះទេ។ បើគ្មានដំណើរការនេះ កំណត់ត្រាសំខាន់បំផុតរបស់តុលាការនឹងមិនអាចចូលមើលបាន ឬនឹងប៉ះពាល់ដល់អ្នកដែលត្រូវអនុវត្តក្នុងនាមតុលាការ។

83. គេអាចប្រមលមើលបានថា មានតម្រូវការធនធានច្រើននៅចុងបញ្ចប់នៃសំណុំរឿង00២ សម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញ។ តុលាការអន្តរជាតិដទៃទៀតក៏ត្រូវវិនិយោគពេលវេលានិងធនធានជាច្រើនក្នុងដំណើរការនេះផងដែរ[104]។ ដំណើរការនេះត្រូវបានរំពឹងទុកយ៉ាងច្បាស់នៅក្នុងសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញ។ ។ មុនពេលផ្ទេរសំណុំរឿង00២ ទៅអង្គជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខ្លួនមានលទ្ធភាពមានកម្រិតក្នុងការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដោយមូលហេតុនៃ "ការកាត់បន្ថយបុគ្គលិក" ប៉ុន្តែបញ្ជាក់ច្បាស់ថា ដំណើរការមួយអាចត្រូវការអនុវត្តដោយអង្គជំនុំជម្រះនៅចុងកិច្ចដំណើរការនីតិវិធី[105]។ ប្រសិនបើធនធានត្រឹមត្រូវពុំទាន់បានកំណត់ជាថវិកាសម្រាប់ដំណើរការនេះទេ ធនធានទាំងនោះត្រូវតែរកឱ្យបានឥឡូវនេះ ផ្នែកស្នូលនៃដំណើរការតុលាការ មិនអាចគ្រាន់តែបំបាត់ចោល ដោយសារតែការចំណាយ ឬការរៀបចំផែនការមិនគ្រប់គ្រាន់នោះឡើយ។

84. សម្រាប់ផ្នែករបស់ខ្លួន សហមេធាវីនាំមុខស្នើសុំផ្តួចផ្តើមដំណើរការមួយដែលរួមមាន (i) ពិនិត្យពេញលេញទៅលើឯកសារដើមបណ្តឹងរដ្ឋប្បវេណី និង (ii) ជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ ដំណើរការនេះនឹងកំណត់អាទិភាពដើមបណ្តឹងរដ្ឋប្បវេណីដែលឯកសាររបស់ពួកគេមាននៅក្នុងភស្តុតាង ដើម្បីកំណត់អត្តសញ្ញាណ និង ពិភាក្សាអំពីសម្ភារៈរសើបដែលមាននៅក្នុងឯកសាររបស់ពួកគេ ដែលអាចត្រូវបានកោសលុប។ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលមិនមាននៅក្នុងភស្តុតាងពេល

---

[104] សូមមើលឧទាហរណ៍នៃការវិភាគឆ្នាំ២០០៩ ទាក់ទិននឹងសេចក្តីត្រូវការនៃមុខងារដែលនៅសេសសល់របស់តុលាការ ICTY និង ICTR រួមទាំងបណ្ណសារផងដែរ ដែលកត់សម្គាល់នូវការប្រឈមដែលពាក់ព័ន្ធក្នុងការដោះស្រាយសម្ភារៈឯកសារសម្ងាត់ និងការណ៍ដែលថាវាគួរត្រូវបានអនុវត្តដោយប្រើប្រាស់ "ជំនាញការ និងចំណេះដឹង" របស់បុគ្គលិកដែលមានស្រាប់របស់តុលាការមុននឹងធ្វើការកាត់បន្ថយបុគ្គលិក៖ អង្គការសហប្រជាជាតិ៖ របាយការណ៍របស់អគ្គលេខាធិការស្តីពីទិដ្ឋភាពរដ្ឋបាល និងថវិកានៃជម្រើសលទ្ធភាព ទីតាំងសម្រាប់បណ្ណសារនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌសម្រាប់ប្រទេស រវ៉ាន់ដា និងអសនៈនៃយន្តការដែលសេសសល់សម្រាប់សាលាក្តី S/2009/258 ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ជាពិសេស នៅកថាខណ្ឌ៨៩។

[105] ឯកសារលេខ **E467/6** ដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងមកជាឯកសារសាធារណៈ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ៧ និង១១។

នោះអាចអនុវត្តក្នុងដំណើរការស្រដៀងគ្នា ដើម្បីកំណត់ថាតើដើមបណ្តឹងមានបំណងយល់ព្រមទៅលើការធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះឯកសារ ឬផ្នែកនានានៃឯកសាររបស់ពួកគេឬយ៉ាងណា។

85. ដំណើរការដែលបានស្នើនេះ រួមមានជាជំហានៗដូចខាងក្រោម៖

(១) ការពិនិត្យពេញលេញទៅលើឯកសារ នឹងត្រូវបានអនុវត្តដើម្បីកំណត់អត្តសញ្ញាណពត៍មានដែលអាចរសើប ដែលមាននៅក្នុងឯកសារដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ ៤០០០ ដែលជាភស្តុតាងនឹងត្រូវបានផ្តល់អាទិភាព។ ពត៍មានដែលរសើបនឹងត្រូវបានកំណត់អត្តសញ្ញាណដោយប្រើពិធីការដែលបានព្រមព្រៀងជាមុនដោយផ្អែកលើការណែនាំរបស់អង្គជំនុំជម្រះ។ ឧទាហរណ៍៖

(ក) ត្រូវបានស្នើឡើងឱ្យចាត់ទុកព័ត៌មានទំនាក់ទំនងលម្អិត ព័ត៌មានលម្អិតនៃស្ថានភាពសុខភាពផ្លូវកាយនិងផ្លូវចិត្ត និងភស្តុតាងដែលបានប្រឡាក់ដោយការធ្វើទារុណកម្ម ដោយសន្មតថាសមស្របសម្រាប់ការកោសលុប លើកលែងតែមានបើមានការបញ្ជាក់យ៉ាងច្បាស់ផ្ទុយទៅវិញ (ឧទាហរណ៍ ព័ត៌មានដែលត្រូវបានបញ្ចូលក្នុងសក្ខីកម្មជាសាធារណៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាលក្រមរបស់តុលាការ)។

(ខ) សហមេធាវីនាំមុខបានកំណត់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៥២៣ នាក់ ដែលឯកសាររបស់ពួកគេនិយាយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង/ឬអំពើហិង្សាផ្លូវភេទ។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីខាងលើ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨៤៩ នាក់ ត្រូវបានស្គាល់ថាមានទំនាក់ទំនងជាមួយឯកសារដែលមានលេខសម្គាល់ E3 (ពោលគឺឯកសារក្នុងភស្តុតាង)។ ការពិនិត្យពេញលេញទៅលើឯកសារនឹងបញ្ជាក់ថាតើពត៍មាននោះអាចមានភាពរសើបខ្លាំងឬយ៉ាងណា ហើយជាពិសេសថាតើវាកំណត់ *អត្តសញ្ញាណ* នៃជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ឬការរៀនអាពាហ៍ពិពាហ៍ដោយបង្ខំ។

(គ) ឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលដាក់ឈ្មោះចារីតាមការចោទប្រកាន់នឹងត្រូវបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន ដើម្បីកំណត់ករណីជាក់ស្តែងនានាដែលអាចបង្កើតហានិភ័យនៃការសងសឹក ឬទំនាស់។

(២) ត្រូវបានរំពឹងទុកក្នុងករណីជាច្រើនថា ការពិនិត្យពេញលេញទៅលើឯកសារនឹងគ្រប់គ្រាន់ដើម្បីស្នើការកោសលុបដែលចាំបាច់។ នៅពេលដែលមានការសង្ស័យ ការប្រជុំនឹងត្រូវបានរៀបចំជាមួយដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដើម្បីពិគ្រោះជាមួយពួកគាត់អំពីចំណង់ចំណូលចិត្តរបស់ពួកគាត់

ទាក់ទងនឹងពត៌មានដែលការចោទសួរ។ នៅទីកន្លែងដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវជួប ការត្រួតពិនិត្យនឹងត្រូវបានអនុវត្តជាដំបូងនូវពត៌មាន (មិនមែនភស្តុតាង) ផ្សេងទៀតនៅក្នុងសំណុំរឿងដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីនោះ ដើម្បីរឿងទាំងនេះអាចដោះស្រាយបានជាមួយគ្នានៅក្នុងការពិភាក្សាតែមួយ។

(៣) ផ្អែកលើជំហានទាំងនេះ សំណើសុំធ្វើចំណាត់ប្រភេទនិងការកោសលុបលើឯកសារដើម បណ្តឹងរដ្ឋប្បវេណីក្នុងភស្តុតាង នឹងត្រូវដាក់ជូនអង្គជំនុំជម្រះ ដែលពេលនោះអង្គជំនុំជម្រះអាចសម្រេចក្នុងពេលវេលាសមស្រប និងដោយពិចារណាលើចម្លើយតបពីភាគីផ្សេងទៀត។ ដើម្បីសម្របសម្រួលចម្លើយតបបែបនេះ សហមេធាវីនាំមុខស្នើរៀបចំសារណាមួយឈុតអមជាមួយ ដែលនឹងពន្យល់ខ្លឹមសារទូទៅនៃសនិទានភាពនៃប្រភេទការកោសលុបមួយចំនួនដែលបានស្នើឡើង។

(៤) នៅពេលដែលសារណាត្រូវបានធ្វើឡើងលើសម្ភារៈភស្តុតាង ដែលសន្មតថាសាធារណៈ យោងតាមសេចក្តីណែនាំអនុវត្តលើការធ្វើចំណាត់ថ្នាក់ឡើងវិញនោះ ដំណើរការទៅមុខទៀតនឹងត្រូវផ្តួចផ្តើមដើម្បីដោះស្រាយឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ ដែលមិនមាននៅក្នុងភស្តុតាង ដោយយោងតាមនីតិវិធីស្រដៀងគ្នា។

## ៧. សំណើ

86. ផ្អែកលើអំណះអំណាងខាងលើ សហមេធាវីនាំមុខគោរពស្នើសុំអង្គជំនុំជម្រះមេត្តា៖

(ក) **គាំទ្រ** គោលការណ៍នៃឯកជនភាព និងការយល់ព្រមដែលទទួលបានព័ត៌មានគ្រប់គ្រាន់ ពាក់ព័ន្ធនឹងការកោសលុបឯកសារដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងមុនពេលមានការធ្វើចំណាត់ប្រភេទឡើងវិញណាមួយ

(ខ) **បញ្ជាក់** ថា ខ្លួនមានអំណាចបង្គាប់ឱ្យធ្វើការកោសលុបឯកសារមុនពេលធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ អនុលោមតាមសេចក្តីណែនាំអនុវត្ត ក្នុងនោះរួមមានគោលបំណងនៃការការពារឯកជនភាព និង ចៀសវាងការសងសឹក។

(គ) **បញ្ជាក់** ថា ឯកសារដើមបណ្តឹងរដ្ឋប្បវេណីដែលស្ថិតនៅក្រៅខ្លឹមសារមាត្រា៤ នៃសេចក្តីណែនាំអនុវត្ត នឹងមិនត្រូវធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ ដោយគ្មានសំណើបង្ហាញពីការយល់ព្រមដែលទទួលបានព័ត៌មានគ្រប់គ្រាន់ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធឡើយ។

(ឃ) **ណែនាំ** ភាគីឱ្យរៀបចំសារណាពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញ ក្នុងនោះរួមមាន សំណើសុំធ្វើការកោសលុបសម្ភារៈភស្តុតាង មុនពេលចេញសាលដីកាស្ថាពរ។

(ង) **បង្គាប់** ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញជាបន្ទាន់ជាឯកសារសាធារណៈ (រហូតដល់ និង ផ្អែកតាមលទ្ធផលនៃដំណើរការធ្វើចំណាត់ប្រភេទឡើងវិញពេញលេញ) លើឯកសារដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងរឿងក្តីទាំងអស់ដែលត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញថាសាធារណៈ ដោយកំហុស ឬដោយគ្មានការកោសលុបត្រឹមត្រូវដែលរំលោភលើសេចក្តីណែនាំអនុវត្ត។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០២១ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |
| | Megan HIRST<br>សហមេធាវីនាំមុខអន្តរជាតិ | រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |